

សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE OF
HUMAN RIGHTS



# “ភរិយាល្អ”

## អ្នកធ្វើយុទ្ធនាការដីធ្លីជាស្ត្រី និងផលប៉ះពាល់នៃភាពសកម្មនិយមសិទ្ធិមនុស្ស

របាយការណ៍ចេញ
ខែវិច្ឆិកា ឆ្នាំ២០១៩

# “ភរិយាល្អ”

## អ្នកធ្វើយុទ្ធនាការដីធ្លីជាស្ត្រី និងផលប៉ះពាល់នៃសកម្មភាពនិយមសិទ្ធិមនុស្ស

របាយការណ៍ចេញខែវិច្ឆិកា ឆ្នាំ២០១៤


សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:**
បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ច:**
ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារ:**
អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:**
ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានា:**
ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:**
អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍:**
ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយ-ការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


## សារតា ទំព័រ១

ស្ត្រី និងភាពសកម្មនិយមដីធ្លី ១

វិធីសាស្ត្រសិក្សា ១

កំណត់ត្រាលើលទ្ធផល ២

## លទ្ធផល ទំព័រ៤

ការផ្លាស់ប្តូរ និងទំនាក់ទំនង
រវាងបុរស និងស្ត្រី ៤

ភាពតានតឹង និងអំពើហិង្សា ៥

ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ៧

ការប៉ះពាល់ផ្នែកសតិអារម្មណ៍ ៩

ការឆ្លើយតបរបស់ស្ត្រីចំពោះអំពើហិង្សា ១០

## សេចក្តីសន្និដ្ឋាន ទំព័រ១៤

## អនុសាសន៍ ទំព័រ១៥





គំរបមុខ៖ សកម្មជនស្ត្រីចូលរួមការទាមទារក្នុងទិវាសិទ្ធិនារីអន្តរជាតិ
ក្នុងរាជធានីភ្នំពេញ កាលពីខែមីនា ឆ្នាំ២០១៤



សកម្មជនស្ត្រីបួងសួងក្នុងពេលតវ៉ានៅដងផ្លូវ ក្នុងរាជធានីភ្នំពេញ កាលពីខែមីនា ឆ្នាំ២០១៤

# សាវតា

## ស្ត្រី និង ភាពសកម្មនិយមដីធ្លី

ក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយប្រជាពលរដ្ឋកម្ពុជារាប់ម៉ឺននាក់ត្រូវបានបណ្តេញចេញពីទីលំនៅដ្ឋាន និងដីស្រែរបស់អ្នកទាំងនោះដោយការបង្ខិតបង្ខំ ហើយអ្នកខ្លះទៀតទទួលរងការគំរាមកំហែងឲ្យផ្លាស់ទីលំនៅ។ ក្នុងករណីភាគច្រើន អាជ្ញាធរមានការជាប់ពាក់ព័ន្ធនៅក្នុងជម្លោះដីធ្លី ដោយតាមរយៈការផ្តល់ដីសម្បទាន ឬការប្រើប្រាស់កងកម្លាំងរបស់រដ្ឋដើម្បីបំភ័យប្រជាពលរដ្ឋនិងបណ្តេញពួកគាត់ចេញពីដីធ្លីរបស់ពួកគាត់ ហើយនិងបំផ្លិចបំផ្លាញផ្ទះសំបែងទៀតផង។[១]

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ សហគមន៍រងគ្រោះជាច្រើនបានកសាងរៀបចំខ្លួន ដើម្បីទប់ទល់ទៅនឹងការបណ្តេញចេញ ឬក៏ដើម្បីស្វែងរកសំណងដែលសមស្របទៅនឹងអ្វីដែលពួកគាត់បានបាត់បង់។ ស្ត្រីខ្មែរបានបង្ហាញខ្លួននៅជួរមុខនៃយុទ្ធនាការទាំងនេះ ដែលក្នុងនោះ មានស្ត្រីជាច្រើននាក់បានក្លាយខ្លួនទៅជាអ្នកដឹកនាំសហគមន៍ និងអ្នកតស៊ូមតិសិទ្ធមនុស្សដ៏មានប្រសិទ្ធភាព ។

អង្គការលីកាដូ ធ្វើការយ៉ាងជិតស្និតជាមួយនិងសហគមន៍ជាច្រើនពាក់ព័ន្ធក្នុងវិវាទដីធ្លី។ អង្គការលីកាដូគាំទ្រសហគមន៍ទាំងនោះក្នុងការធ្វើការតស៊ូមតិរបស់អ្នកទាំងនោះ ដោយតាមរយៈការផ្តល់ជំនួយផ្នែកសម្ភារៈ និងធនធានផ្សេងៗ ហើយអង្គការលីកាដូ ក៏បានផ្តល់នៅសេវាជំនាញផ្សេងៗ ដូចជាសេវាកម្មផ្នែកច្បាប់ ផ្នែកការងារសង្គម និងផ្នែកសេវាពេទ្យ។ ទាំងអស់នេះ គឺដើម្បីធានាថាសហគមន៍ទាំងនោះនៅតែអាចបន្តភាពសកម្មនិយមរបស់អ្នកទាំងនោះបាននៅពេលដែលមានបញ្ហាកើតឡើង។

ជាលទ្ធផលនៃការងារនេះ អង្គការលីកាដូ មានទំនាក់ទំនងទៀងទាត់ និងជិតស្និតជាមួយនឹងស្ត្រីសកម្មជនដីធ្លី ហើយដូច្នេះ អង្គការលីកាដូ ក៏បានដឹងពីឧបសគ្គជាច្រើនដែលអ្នកទាំងនេះជួបប្រទះ។ អ្នកទាំងនោះមិនត្រឹមតែទទួលរងការគំរាមកំហែង និងការបំភ័យពីរាជរដ្ឋាភិបាល និងការប្រើប្រាស់កម្លាំងហើយនិងច្បាប់ជាញឹកញាប់ទៅលើពួកគាត់ប៉ុណ្ណោះទេ អ្នកទាំងនោះថែមទាំងកំពុងតែរែកបន្ទុកឥតឈប់ឈរ នៃអនាគតមិនច្បាស់លាស់មួយ សំរាប់អ្នកទាំងនោះ និងគ្រួសាររបស់អ្នកទាំងនោះទៀតផង។

## វិធីសាស្ត្រសិក្សា

កិច្ចសន្ទនាជាមួយនឹងស្ត្រីសកម្មជនដីធ្លីក្នុងអំឡុងពេលការងាររបស់អង្គការលីកាដូ បានបង្ហាញអោយឃើញថា អ្នកទាំងនោះបានចំណាយតម្លៃរបស់ខ្លួនយ៉ាងច្រើន សម្រាប់ភាពសកម្មនិយមរបស់អ្នកទាំងនោះ គឺការរងទុក្ខយ៉ាងធ្ងន់ធ្ងរមិនត្រឹមតែផ្នែកសេដ្ឋកិច្ច និងការប៉ះទង្គិចផ្នែកសតិអារម្មណ៍ប៉ុណ្ណោះទេ អ្នកទាំងនោះជាញឹកញាប់ ក៏ថែមទាំងទទួលរងទុក្ខពីអំពើហិង្សាក្នុងគ្រួសារ និងការបែកបាក់គ្រួសារផងដែរ។ ដើម្បីស្វែងយល់អោយកាន់តែច្បាស់អំពីផលប៉ះពាល់នៃភាពសកម្មនិយមសិទ្ធដីធ្លីទៅលើស្ត្រី និងជាពិសេស

[១] នៅខែមេសា ឆ្នាំ២០១៤ លីកាដូបានចេញផ្សាយទិន្នន័យដែលបង្ហាញថានៅក្នុងតំបន់មួយចំនួនក្នុងប្រទេសដែលនៅក្រោមការត្រួតពិនិត្យរបស់អង្គការ លីកាដូ ចំនួនប្រជាជនដែលប៉ះពាល់ដោយសារវិវាទដីធ្លីដែលពាក់ព័ន្ធនឹងអាជ្ញាធររដ្ឋ បានឈានទៅដល់កន្លះលាននាក់ http://www.licadho-cambodia.org/pressrelease.php?perm=342

គឺទំនាក់ទំនងរវាងភាពសកម្មនិយម និងអំពើហិង្សាក្នុងគ្រួសារហើយ និងការបែកបាក់គ្រួសារ អង្គការលីកាដូ បានធ្វើការសម្ភាសន៍ជាមួយ ស្ត្រីចំនួន ២៤នាក់ ដែលពាក់ព័ន្ធនៅក្នុងយុទ្ធនាការប្រឆាំងនឹងការ បណ្តេញចេញ និងការរំលោភយកដីធ្លី។ ចំនួនពាក់កណ្តាលនៃស្ត្រី ទាំងនោះ គឺមកពីសហគមន៍ជនបទ និងពាក់កណ្តាលទៀតមកពីរាជ ធានីភ្នំពេញ។ អ្នកទាំងអស់គ្នា គឺធ្លាប់បានចូលរួមនៅក្នុងយុទ្ធនាការ អស់រយៈពេលជាច្រើនឆ្នាំ ហើយក្នុងនោះស្ត្រី ៨នាក់ គឺមានភាពសកម្ម យ៉ាងខ្លាំងក្លា និងបច្ចុប្បន្នកំពុងធ្វើការស្ទើរតែពេញម៉ោងជាអ្នកធ្វើ យុទ្ធនាការ។ ស្ត្រីមួយចំនួនក្នុងចំនោមស្ត្រីទាំងអស់ ត្រូវបានចាប់ខ្លួន ហើយត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារដោយសារតែភាពសកម្មនិយម របស់អ្នកទាំងនោះ។

អ្នកចូលរួមបទសម្ភាសន៍ត្រូវបានជ្រើសរើស ដោយផ្អែកជា ចំបងទៅលើបទពិសោធន៍ នៃការធ្លាប់ឆ្លងកាត់អំពើហិង្សាក្នុងគ្រួសារ ឬការបែកបាក់គ្រួសារ ប៉ុន្តែទោះបីជាយ៉ាងណា ក៏មិនមែនពឹងផ្អែកលើ ករណីនេះទាំងស្រុងនោះទេ។ ដូច្នេះអ្នកចូលរួមបទសម្ភាសន៍មិនមែន តំណាងអោយសហគមន៍ទាំងមូលរបស់អ្នកទាំងនោះនោះទេ។

បទសម្ភាសន៍ទាំងអស់ ចាប់ផ្តើមជាមួយនឹងសំនួរបើកមួយ អំពីថាតើជម្លោះដីធ្លី បានធ្វើអោយមានផលប៉ះពាល់យ៉ាងដូចម្តេចទៅ លើជីវិតរបស់អ្នកទាំងនោះ។ ក្នុងករណីភាគច្រើន សំនួរនេះបាននាំ អោយឈានទៅដល់ការពិភាក្សាដ៏ទូលំទូលាយមួយអំពីផលប៉ះពាល់ ផ្សេងៗ ដែលរួមមានដូចជាផលប៉ះពាល់ទៅលើគ្រួសារ និងពេលខ្លះ អំពើហិង្សាក្នុងគ្រួសារទៀតផង។ វាក៏បានគ្របដណ្តប់ទៅលើផល ប៉ះពាល់នៃការបណ្តេញចេញ និងការបាត់បង់ដីធ្លី ហើយក៏ដូចជាផល ប៉ះពាល់ជាក់លាក់មួយចំនួននៃភាពសកម្មនិយមរយៈពេលវែង។ អ្នក ទាំងនោះ មិនបានបែងចែកផលប៉ះពាល់ទាំងនោះជាប្រភេទផ្សេងៗ គ្នាទេ ហើយពួកគាត់តែងតែពន្យល់ថាផលប៉ះពាល់ទាំងនោះមាន ទាក់ទងគ្នាទៅវិញទៅមក។ ដើម្បីធ្វើការទំនាក់ទំនងជាមួយនិងភាព ស្មុកស្មាញ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នៃវិវាទដីធ្លី របាយការណ៍ នេះមានរួមបញ្ចូលការពិភាក្សានៃផលប៉ះពាល់ទាំងអស់ ដែលបាន លើកឡើងដោយស្ត្រីដែលត្រូវបានសម្ភាសន៍ទាំងនោះ ហើយផលប៉ះ ពាល់ទាំងនោះមិនមែនរួមមានត្រឹមតែអំពើហិង្សាក្នុងគ្រួសារ និងការ បែកបាក់គ្រួសារ និងមិនមែនមានតែផលប៉ះពាល់នៃភាពសកម្ម និយមនោះទេ។

## កំណត់ត្រាលើលទ្ធផល

មានភាពដូចគ្នារវាងបទពិសោធន៍របស់ស្ត្រី ដែលទទួលការ សម្ភាសន៍ទាំងអស់ ប៉ុន្តែមានសារៈសំខាន់ក្នុងការកត់សំគាល់ថាផល ប៉ះពាល់នៃវិវាទដីធ្លីមានភាពខុសៗគ្នា ដោយផ្អែកទៅលើកាលៈទេសៈ នៃសហគមន៍ផ្សេងៗគ្នាទាំងនោះ។ បទពិសោធន៍របស់សហគមន៍ ទីក្រុង ខុសប្លែកពីបទពិសោធន៍របស់សហគមន៍នៅតំបន់ជនបទ ហើយសហគមន៍ដែលត្រូវបានបណ្តេញចេញទាំងនោះ ជួបប្រទះភាព លំបាកធ្ងន់ធ្ងរជាងសហគមន៍ ដែលនៅតែបន្តរស់នៅក្នុងលំនៅដ្ឋាន របស់គាត់ ឬក៏នៅតែកាន់កាប់ដីស្រែចំការរបស់ពួកគាត់។ កាលៈទេសៈ ជាក់លាក់កើតឡើងមុនពេលជម្លោះដីធ្លីរបស់ស្ត្រីម្នាក់ៗ ក៏មានភាពខុសប្លែកគ្នាដែរ ហើយវាមានឥទ្ធិពលទៅលើរបៀបដែល ជម្លោះដីធ្លីប៉ះពាល់ទៅលើអ្នកទាំងនោះ។ អ្នកដែលរស់នៅក្នុង សហគមន៍ទីក្រុងជាទូទៅមានស្ថានភាពល្អជាង មានការអប់រំច្រើន ជាង និងមិនមានភាពឯកោច្រើនដូចអ្នកដែលរស់នៅក្នុងសហគមន៍ ជនបទនោះទេ។ ភាគច្រើននៃអ្នកដែលត្រូវបានសម្ភាសន៍ ដែលរស់ នៅតំបន់ជនបទ គឺកំពុងតែរស់នៅក្នុងស្ថានភាពលំបាកធ្ងន់ធ្ងររួចទៅ ហើយ មុនពេលដែលជម្លោះដីធ្លីរបស់ពួកគាត់កើតឡើង។ អ្នកទាំង នោះមិនត្រឹមតែក្រីក្រនោះ ប៉ុន្តែជានិច្ចជាកាលតែងតែទទួលរងផលប៉ះ ពាល់ដោយសារពិការភាព ការញៀនស្រា និងអំពើហិង្សាក្នុងគ្រួសារ ដែលមានពីមុនមកទៅហើយ។ ការរកឃើញខាងក្រោមនឹងព្យាយាម ឆ្លុះបញ្ចាំងអំពីភាពខុសប្លែកទាំងនេះខ្លះៗ ហើយទន្ទឹមនឹងនេះក៏ ព្យាយាមទាញសេចក្តីសន្និដ្ឋាន អំពីភាពដូចគ្នារវាងបទពិសោធន៍ របស់ស្ត្រីដែលទទួលការសម្ភាសន៍ទាំងអស់។




ស្ត្រីជាកម្មករចូលរួមក្នុងទិវាសិទ្ធិនារីអន្តរជាតិ ក្នុងរាជធានីភ្នំពេញ កាលពីខែមីនា ឆ្នាំ២០១៤

[២] នៅរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានសម្ភាសន៍ជាមួយស្ត្រី ៥នាក់ មកពីសហគមន៍បុរីកីឡា ៦នាក់មកពីសហគមន៍បឹងកក់ និង១នាក់មកពីសហគមន៍ថ្មគោល។ នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប អ្នកស្រាវជ្រាវបានសម្ភាសន៍ស្ត្រី ១២នាក់។ ស្ត្រីទាំងអស់ត្រូវបានសម្ភាសជាបុគ្គលដាច់ៗពីគ្នា ហើយការសម្ភាសន៍ប្រព្រឹត្តឡើងនៅក្នុង ខែមិថុនា និងខែកក្កដា ឆ្នាំ២០១៤។



សកម្មជនស្ត្រីបឹងកក់ ប្រមូលផ្តុំក្នុងសន្និសីទសារព័ត៌មាន ក្នុងរាជធានីភ្នំពេញ កាលពីខែសីហា ឆ្នាំ២០១៤

## ករណីសិក្សា៖ សកម្មជនដីធ្លីនៅទីក្រុង

ក្នុងនាមជាសកម្មជន និងជាអ្នកដឹកនាំសហគមន៍ ជាកិច្ចការលំបាកសម្រាប់ខ្ញុំ ព្រោះស្វាមីរបស់ខ្ញុំមិនចង់ឲ្យខ្ញុំធ្វើការនេះទេ ហើយវាតែងតែធ្វើឲ្យយើងមានជម្លោះជាមួយគ្នា។ មុនពេលខ្ញុំចាប់ផ្តើមធ្វើជាសកម្មជន ជីវិតរបស់ពួកយើងសប្បាយរីករាយ ហើយយើងមានពេលវេលាបន្ទាប់ពីធ្វើការងារដើម្បីនិយាយគ្នា និងរីករាយជាមួយគ្នា ហើយនិងសម្រាក ឬដើរលេង នៅចុងសប្តាហ៍។ អ្វីៗបានផ្លាស់ប្តូរ។

មុនពេលមានជម្លោះ ខ្ញុំជាមេផ្ទះដ៏ល្អ។ ខ្ញុំបានធ្វើម្ហូប និងមើលថែរក្សាកូនស្រីរបស់ខ្ញុំ ហើយធ្វើអ្វីៗបានល្អ។ ប៉ុន្តែនៅពេលដែលខ្ញុំចាប់ផ្តើមធ្វើយុទ្ធនាការខ្ញុំបានឈប់ធ្វើកិច្ចការស្ទើរតែទាំងអស់ដូចនេះគាត់បានចេញពីក្រុមគ្រួសារ ហើយឈប់ជួយជាថវិកាដល់ខ្ញុំ និងកូនស្រីខ្ញុំ ហើយយើងជួបប្រទះ ពេលវេលាដ៏លំបាក។

ហិង្សាក៏កើតមានផងដែរ ហើយគាត់បានបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះ។ អំពើហិង្សា បានកើតឡើងប្រហែលបួនដង ហើយវាធ្ងន់ធ្ងរណាស់។ គាត់ធ្វើឲ្យខ្ញុំឈឺចាប់រាងកាយ។ វាកើតឡើងដោយសារស្វាមីរបស់ខ្ញុំធ្វើការងារ ហើយត្រឡប់មកផ្ទះវិញដោយហត់នឿយ ប៉ុន្តែខ្ញុំមិនមានពេលរៀបចំម្ហូបអាហារ និងធ្វើកិច្ចការជាស្ត្រីមេផ្ទះដ៏ល្អ។ ហើយក៏ដោយសារគាត់ជាយោធា គាត់មិនចង់ឲ្យខ្ញុំចូលរួមក្នុងយុទ្ធនាការនេះទេ។ ជាធម្មតា នៅពេលគាត់ហៅខ្ញុំ ខ្ញុំកំពុងនៅក្រៅធ្វើយុទ្ធនាការ។ នេះក៏ព្រោះតែខ្ញុំមិនត្រឹមតែធ្វើសំរាប់សហគមន៍ខ្ញុំប៉ុណ្ណោះទេ តែខ្ញុំក៏ជួយធ្វើសម្រាប់សហគមន៍ផ្សេងទៀតដែរ ដូចនេះគាត់ខឹងនឹងខ្ញុំអំពីរឿងនេះ។គាត់បានដាក់លក្ខខណ្ឌលើខ្ញុំ ហើយបាននិយាយថាខ្ញុំគួរធ្វើជាស្ត្រីមេផ្ទះដ៏ល្អ ហើយនៅផ្ទះ និងរៀបចំផ្ទះសម្បែង។ ខ្ញុំមិនអាចទទួលបានលក្ខខណ្ឌនេះទេ ដូចនេះគាត់បានចាកចេញ។ គាត់បាននិយាយថា ប្រសិនបើខ្ញុំមិនផ្លាស់ប្តូរគំនិតរបស់ខ្ញុំទេ ហើយនៅតែបន្តភាពសកម្មនិយមរបស់ខ្ញុំ ថ្ងៃណាមួយគាត់នឹងសម្លាប់ខ្ញុំព្រោះគាត់ មិនអាចទ្រាំបានទេ ដូចនេះគាត់ក៏ចាកចេញពីខ្ញុំ។ វាកើតឡើងជិតបីឆ្នាំកន្លងមកហើយ។

ស្ថានភាពសេដ្ឋកិច្ចរបស់ខ្ញុំ ក្រោយពេលដែលស្វាមីរបស់ខ្ញុំចាកចេញពីខ្ញុំ គឺមានការលំបាកយ៉ាងខ្លាំង។ ខ្ញុំមិនបានទៅធ្វើការ ហើយគាត់ឈប់ជួយពួកយើង ព្រោះគាត់ព្យាយាមដាក់សំពាធដល់ខ្ញុំឲ្យឈប់ធ្វើយុទ្ធនាការ។ ខ្ញុំមិនបានទៅរកអាជ្ញាធរឲ្យជួយទេ។ ខ្ញុំមិនបានទុកចិត្តលើអាជ្ញាធរក្នុងតំបន់ទេ ព្រោះពួកគេព្យាយាមឃ្លាំមើល និងតាមដានខ្ញុំ ដូចនេះខ្ញុំមិនជឿទុកចិត្តពួកគេទេ។ ខ្ញុំដឹងថាពួកគេមិនជួយខ្ញុំទេ។ ពួកគេសប្បាយចិត្តប្រសិនបើខ្ញុំមានបញ្ហា។ ប៉ុន្តែខ្ញុំបានទៅរកអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួបមេធាវីបន្ទាប់ពីមានអំពើហិង្សាធ្ងន់ធ្ងរ ព្រោះយើងមានសិទ្ធិរួមលើផ្ទះ ហើយស្វាមីរបស់ខ្ញុំបាននិយាយថា ប្រសិនបើខ្ញុំលែងលះគាត់ ខ្ញុំនឹងបាត់បង់ផ្ទះ។ ខ្ញុំសួរមេធាវីអំពីរឿងនេះ ហើយគាត់និយាយថារឿងនេះមិនត្រឹមត្រូវនោះទេ។

ខ្ញុំមិនបានដាក់ពាក្យលែងលះទេ ព្រោះខ្ញុំដឹងថាវាជាកំហុសខ្ញុំ ហើយខ្ញុំមិនមែនជាស្ត្រីមេផ្ទះដ៏ល្អ ហើយខ្ញុំមិនបានស្តាប់ស្វាមីរបស់ខ្ញុំ។ ប្រពៃណីរបស់យើងនិយាយថាយើងគួរតែស្តាប់ស្វាមីរបស់យើង។ ខ្ញុំបានសម្រេចចិត្ត ជ្រើសរើសសហគមន៍ ហើយបន្តភាពសកម្មនិយមរបស់ខ្ញុំ ហើយគាត់ឈឺចាប់ដោយសាររឿងនេះ។

> "ក្រោយអំពើហិង្សា ខ្ញុំមិនបានទៅរកអាជ្ញាធរឲ្យជួយទេ។ ខ្ញុំមិនបានទុកចិត្តលើ អាជ្ញាធរក្នុងតំបន់ទេ ព្រោះពួកគេព្យាយាមឃ្លាំមើល និងតាមដានខ្ញុំ ដូចនេះខ្ញុំមិនជឿទុក ចិត្តពួកគេទេ។ ខ្ញុំដឹងថាពួកគេ មិនជួយខ្ញុំទេ។ ពួកគេសប្បាយចិត្ត ប្រសិនបើខ្ញុំមានបញ្ហា។"

ឥឡូវខ្ញុំបានស្រុះស្រួលជាមួយស្វាមីខ្ញុំ។ គាត់ត្រឡប់មកវិញប្រហែលមួយខែមកហើយ។ មិត្តភក្តិរបស់គាត់ដែលធ្វើការងារសង្គម បានព្យាយាមពន្យល់គាត់ ថាវាល្អដែលមានភរិយាជាសកម្មជន និងខ្លាំង ហើយគាត់ព្យាយាមសម្របសម្រួលពួកយើង។ ដូចនេះឥឡូវស្វាមីរបស់ខ្ញុំនិយាយថាមិនអីទេក្នុងការធ្វើយុទ្ធនាការ កុំឲ្យតែវាជារឿងនយោបាយ។

ឥឡូវនេះខ្ញុំត្រូវជាមួយស្វាមីខ្ញុំវិញហើយ ប៉ុន្តែខ្ញុំមិនច្បាស់ពីអនាគតទេ ព្រោះខ្ញុំនៅបន្តធ្វើយុទ្ធនាការ។ ខ្ញុំបានចូលរួមតវ៉ាម្សិលមិញ ហើយស្វាមីរបស់ខ្ញុំមានការព្រួយបារម្ភអំពីរឿងនេះ ប៉ុន្តែវាពិបាកក្នុងការមិនចូលរួម។

មុននឹងខ្ញុំចាប់ផ្តើមធ្វើយុទ្ធនាការ ខ្ញុំនៅកន្លែងងងឹត។ ខ្ញុំមិនដឹងអ្វីទាំងអស់នៅក្នុងសង្គម ហើយនិងបញ្ហាក្នុងសង្គម។ ប៉ុន្តែឥឡូវ ខ្ញុំនៅកន្លែងភ្លឺ ព្រោះខ្ញុំដឹងច្រើន ហើយខ្ញុំបានទទួលការបណ្តុះបណ្តាលអំពីច្បាប់ និងការតស៊ូមតិពីអង្គការមិនមែនរដ្ឋាភិបាលជាច្រើន។ ដូចនេះខ្ញុំមានចំណេះដឹងច្រើន ហើយវានឹងធ្វើឲ្យខ្ញុំសប្បាយចិត្តព្រោះខ្ញុំដឹងច្រើនអំពីបញ្ហាដែលកើតមានក្នុងសង្គម។ ខ្ញុំមិនសោកស្តាយអំពីភាពសកម្មនិយមរបស់ខ្ញុំទេ។ ផ្ទុយទៅវិញ ខ្ញុំសប្បាយចិត្ត ព្រោះខ្ញុំបានជួយសង្គម និងសហគមន៍ផ្សេងទៀត ដើម្បីធ្វើឲ្យអ្នកទាំងនោះខ្លាំង ហើយបានចែករំលែកចំណេះដឹង ដូចនេះយើងអាចក្រោកឈរទាំងអស់គ្នា ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំបានចូលរួមចំណែកនៅក្នុងសង្គម។ រាជរដ្ឋាភិបាលនឹងភ័យខ្លាច ព្រោះប្រជាពលរដ្ឋទាំងអស់នឹងរួមសាមគ្គីគ្នា ហើយយើងនឹងជួយគ្នាទៅវិញទៅមក។

## ការផ្លាស់ប្តូរទំនាក់ទំនងរវាងបុរស និងស្រ្តី

ស្ទើរតែទាំងអស់នៃស្រ្តីដែលត្រូវបានសម្ភាសន៍ បាននិយាយថាវិវាទដីធ្លី និងការចូលរួមរបស់ពួកគាត់នៅក្នុងការធ្វើយុទ្ធនាការ បាននាំមកនូវការផ្លាស់ប្តូរមួយ នៅក្នុងទំនាក់ទំនងរបស់អ្នកទាំងនោះ ជាមួយនឹងស្វាមីរបស់អ្នកទាំងនោះ និងចំពោះករណីខ្លះ គឺសាច់ញាតិរបស់អ្នកទាំងនោះ។ ភាពសកម្មនិយមរបស់អ្នកទាំងនោះ គឺមានន័យថាពួកគាត់ ជាញឹកញាប់បានចូលរួមការប្រជុំ និងការតវ៉ាអស់រយៈពេលច្រើនឆ្នាំ ដែលធ្វើឲ្យកាត់បន្ថយពេលវេលា ដែលគាត់ត្រូវចំណាយនៅផ្ទះ ឬ ពេលវេលា ដែលគាត់ត្រូវផ្តល់អោយគ្រួសាររបស់អ្នកទាំងនោះ។ ស្រ្តីដែលឆ្លងកាត់ការផ្លាស់ប្តូរច្រើនជាងគេ គឺជាអ្នកដឹកនាំសហគមន៍ដែលយុទ្ធនាការ របស់អ្នកទាំងនោះស្ទើរតែក្លាយទៅជាសកម្មភាពពេញម៉ោងទៅហើយ។ ស្រ្តីជាច្រើននាក់បានសង្ខេបអំពីផលប៉ះពាល់នៃយុទ្ធនាការ របស់គាត់ទៅលើជីវិតខ្លួនគាត់ ដោយនិយាយថាមុនពេលដែលពួកគាត់ចាប់ផ្តើម ពួកអ្នកទាំងនោះគឺជា "ភរិយាល្អ" ប៉ុន្តែឥឡូវនេះគាត់មានពេលតិចតួចសំរាប់ចំអិនម្ហូបអាហារ សំអាតផ្ទះ និងមើលថែរក្សាក្រុមគ្រួសាររបស់អ្នកទាំងនោះដូចតាមរបៀបប្រពៃណី ហើយដូច្នេះគាត់មិនអាចបន្តហៅខ្លួនឯងថាជា "ភរិយាល្អ" បានទៀតទេ។

> "មុនមានជម្លោះ ខ្ញុំគឺជាមេផ្ទះល្អ។ ខ្ញុំរៀបចំម្ហូប ថែទាំកូនស្រី និងធ្វើអ្វីបានយ៉ាងល្អ។ ប៉ុន្តែនៅពេលខ្ញុំបានចាប់ផ្តើមតវ៉ា ខ្ញុំធ្វើការងារទាំងនោះមិនបានដិតដល់ ដូច្នេះហើយគាត់បានចាក ចោលគ្រួសារ និងឈប់ផ្គត់ផ្គង់ខ្ញុំ និងកូនស្រី។"
>
> សកម្មជនដីធ្លីនៅទីក្រុង

ការបាត់បង់សមត្ថភាពរបស់ស្រ្តី ក្នុងការបំពេញតួនាទីជាភរិយាតាមប្រពៃណី គឺជាប្រភពមួយនៃភាពតានតឹងនៅក្នុងគ្រួសាររបស់ស្រ្តីដែលទទួលការសម្ភាសន៍ស្ទើរតែទាំងអស់ ហើយគាត់បានពិពណ៌នាថាពួកគាត់ត្រូវប្រឈមមុខការដោះស្រាយ ជាមួយនឹងការត្អូញត្អែរស្រដៀងៗគ្នាពីស្វាមីរបស់អ្នកទាំងនោះ។

ជាដំបូងបង្អស់ ស្វាមីពួកគាត់មានការតឹងតែង អំពីពេលវេលាលើសលុប ដែលពួកគាត់ចំណាយនៅខាងក្រៅផ្ទះ និងការពិតដែលគាត់មាន ពេលវេលាតិចតួច ដើម្បីមើលថែរក្សាក្រុមគ្រួសាររបស់អ្នកទាំងនោះ។ ការរិះគន់ជាទូទៅ និងជាក់លាក់មួយ គឺការខកខានក្នុងការរៀបចំអាហារ។ នេះ គឺជាប្រភពមួយដ៏សំខាន់នៃភាព តានតឹង និងការឈ្លោះប្រកែក ដែលនៅពេលបុរសត្រលប់មកពីធ្វើការ ជាញឹកញាប់គាត់ឃើញថា ភរិយារបស់គាត់នៅខាងក្រៅផ្ទះនៅឡើយ ហើយមិនមានអ្វីទាល់តែសោះសំរាប់គាត់បរិភោគ។

ស្រ្តីមួយចំនួនបានបង្ហាញថាស្វាមីរបស់គាត់ក៏បានបញ្ចេញកំហឹងផងដែរចំពោះការអន់ចិត្តផ្នែកផ្លូវភេទ។ ជាការពិតស្រ្តីទាំងនេះ តែងតែចេញពីផ្ទះរហូតដល់យប់ជ្រៅ និងត្រលប់មកវិញអស់កម្លាំង មានន័យថាពួកគាត់មិនមានអារម្មណ៍ផ្លូវភេទសំរាប់ស្វាមីរបស់គាត់ ដូចដែរគាត់ធ្លាប់មានពីមុនមក។ នេះបានធ្វើអោយមានភាពតានតឹង នៅក្នុងទំនាក់ទំនងរបស់ស្រ្តីជាច្រើននាក់ដែលត្រូវបានសម្ភាសន៍ ហើយស្រ្តី ៣ ឬ ៤ នាក់ បាននិយាយថាប្តីពួកគាត់មិនត្រឹមតែបង្ហាញភាពអាក់អន់ចិត្តចំពោះរឿងនេះទេ ប៉ុន្តែបែបជាចោទប្រកាន់គាត់ថាមានមិត្តប្រុស និងចោទថាអ្នកទាំងនោះថាមិននិយាយការពិតអំពីរឿងចេញពីផ្ទះទៅធ្វើយុទ្ធនាការ។



ប្រជាពលរដ្ឋមកពីខេត្តក្រចេះ ដើម្បីដាក់ញត្តិជូននាយករដ្ឋមន្រ្តី ក្នុងរាជធានីភ្នំពេញ កាលពីខែសីហា ឆ្នាំ២០១៤

ស្ត្រីភាគច្រើនបាននិយាយថា តួនាទីរបស់អ្នកទាំងនោះនៅក្នុងការសំរេចចិត្តនៅក្នុងគ្រួសារក៏មានការផ្លាស់ប្តូរផងដែរ បន្ទាប់ពីពួកគាត់បានចាប់ផ្តើមចូលរួមនៅក្នុងភាពសកម្មនិយមរបស់សហគមន៍ ហើយនេះគឺជាអ្វីម្យ៉ាងដែលស្វាមីរបស់ពួកគាត់ពិបាកទទួលយក។ អ្នកទាំងនោះបានពន្យល់ថា កាលពីមុនគាត់គោរពតាមរាល់ការសម្រេចចិត្តរបស់ស្វាមីគាត់ទោះបីជាស្ត្រីទាំងនោះមិនយល់ស្របក៏ដោយ។ បច្ចុប្បន្ន ពួកគាត់បញ្ចេញគំនិតរបស់គាត់ដោយមិនខ្លាចបង្ហាញការមិនយល់ស្របជាមួយនិងស្វាមីរបស់គាត់ទេ ហើយគាត់ធ្វើការសម្រេចចិត្តដោយខ្លួនឯងច្រើនជាងមុនទៀតផង។

នៅក្នុងសហគមន៍មួយ អ្នកដឹកនាំជាច្រើននាក់បានទទួលជោគជ័យក្នុងការទាមទារប្លង់កម្មសិទ្ធដីធ្លី ប៉ុន្តែអ្នកទាំងនោះបានសម្រេចចិត្តបន្តធ្វើយុទ្ធនាការរហូតដល់មនុស្សគ្រប់គ្នានៅក្នុងសហគមន៍ទទួលបានប្លង់កម្មសិទ្ធដីធ្លីដែរ។ដោយសារតែមូលហេតុនេះ ស្វាមីរបស់អ្នកទាំងនោះនិងសមាជិកគ្រួសារដទៃទៀតបានចោទប្រកាន់ថាពួកគាត់កំពុងតែពេញចិត្ត ទៅនិងការចាប់អារម្មណ៍និងកេរ្តិ៍ឈ្មោះដែលជាលទ្ធផលបានមកពីភាពសកម្មនិយមរបស់ពួកគាត់ ហើយបានចោទប្រកាន់ថាពួកគាត់បានទុកចោលគ្រួសារដើម្បីបន្តទទួលបានប្រជាប្រិយភាពទាំងនេះ។



ប្រជាពលរដ្ឋមកពីឃុំជីខលើ តវ៉ាប្រឆាំងក្រុមហ៊ុនស្ករអំពៅ ក្នុងខេត្តកោះកុង កាលពីខែតុលា ឆ្នាំ២០១៤

## ភាពតានតឹង និងអំពើហិង្សា

> "គាត់មិនបានផ្តល់ការគាំទ្រនោះទេ ជាពិសេសនៅពេលខ្ញុំទៅភ្នំពេញ។ គាត់ស្តីបន្ទោសខ្ញុំថាខ្ញុំទៅដើរលេង ប៉ុន្តែខ្ញុំនៅ តែទៅ។ គាត់បាននិយាយថា ខ្ញុំគ្រាន់តែទៅដើម្បីសប្បាយខ្លួនឯង ហើយថាខ្ញុំមិនខ្វល់ពីគ្រួសារនោះទេ។ គាត់សប្បាយចិត្តនៅពេលខ្ញុំបានដីធ្លីមកវិញ ប៉ុន្តែ គាត់មិនបានសសើរខ្ញុំ នូវអ្វីដែលខ្ញុំបានធ្វើនោះទេ។"
>
> សកម្មជនដីធ្លីនៅជនបទ

ស្ទើរតែទាំងអស់នៃស្ត្រី ដែលត្រូវបានសម្ភាសន៍ បាននិយាយថា តួនាទីថ្មីរបស់អ្នកទាំងនោះ និងការផ្លាស់ប្តូរនៅក្នុងទំនាក់ទំនង របស់គាត់ជាមួយនឹងស្វាមីបាននាំអោយឈានទៅដល់ ការឈ្លោះប្រកែកគ្នា។ ក្នុងនោះស្ត្រី ៥នាក់បាននិយាយថា ការឈ្លោះប្រកែកគ្នាទាំងនេះបានឈានទៅដល់ការប្រើអំពើហិង្សា ដែលពួកគាត់បានសង្កេតឃើញថា ជាលទ្ធផលផ្ទាល់ដែលកើតឡើងមកពីតួនាទី របស់គាត់ជាអ្នកធ្វើយុទ្ធនាការ។ ៤នាក់ក្នុងចំណោមស្ត្រី ៥នាក់ គឺជាអ្នកដឹកនាំសហគមន៍ ហើយបាននិយាយថាស្វាមីរបស់គាត់បានប្រាប់គាត់ថា គាត់ត្រូវតែជ្រើសរើសរវាងគ្រួសារ និងសហគមន៍។ អំពើហិង្សាចាប់ផ្តើមនៅពេលដែលពួកគាត់មិនព្រមបញ្ឈប់ភាពសកម្មនិយមរបស់អ្នកទាំងនោះ។ អ្នកដឹកនាំសហគមន៍ទាំង៤នាក់ បាន

## ករណីសិក្សា

ខ្ញុំតែងតែចូលរួមក្នុងយុទ្ធនាការ។ ខ្ញុំបានចាប់ផ្តើមនៅឆ្នាំ២០០២។ ខ្ញុំបានមករាជធានីភ្នំពេញ ដើម្បីធ្វើយុទ្ធនាការ។ ស្វាមីរបស់ខ្ញុំ បានចូលរួមជាមួយខ្ញុំនៅលើកដំបូង ប៉ុន្តែបន្ទាប់ពីនោះមានតែខ្ញុំទេ។ គាត់មិនបានផ្តល់ការគាំទ្រនោះទេ ជាពិសេសនៅពេលខ្ញុំទៅភ្នំពេញ។ គាត់ស្តីបន្ទោសខ្ញុំថាខ្ញុំទៅដើរលេង ប៉ុន្តែខ្ញុំនៅតែទៅ។ គាត់បាននិយាយថា ខ្ញុំគ្រាន់តែទៅដើម្បីសប្បាយខ្លួនឯង ហើយថាខ្ញុំមិនខ្វល់ពីគ្រួសារនោះទេ។ គាត់សប្បាយចិត្តនៅពេលខ្ញុំបានដីធ្លីមកវិញ ប៉ុន្តែគាត់មិនបានសសើរខ្ញុំ នូវអ្វីដែលខ្ញុំបានធ្វើនោះទេ។

គាត់បានប្រើហិង្សាផ្លូវកាយមកលើខ្ញុំ ជាច្រើនដង ហើយជាច្រើនឆ្នាំចាប់តាំងពីមានកូនដំបូង។ ជាធម្មតា គាត់វាយក្បាលនិងមុខខ្ញុំ។ឆ្នាំមុន គាត់វាយដំខ្ញុំយ៉ាងខ្លាំងពីរដង ម្តងដោយប្រើបន្ទះឫស្សីវាយលើក្បាលខាងក្រោយ ហើយម្តងទៀតដោយប្រើដំបងឈើវាយមកលើខ្ញុំ រហូតដល់ខ្ញុំសន្លប់។ គាត់ក៏វាយដំកូនផងដែរ។ ខ្ញុំមានកូន៤នាក់ បងគេអាយុ១៦ឆ្នាំ ហើយពៅគេអាយុ៩ឆ្នាំ។ អំពើហិង្សាបានកើតឡើង មុនពេលមានជម្លោះដីធ្លីបានចាប់ផ្តើម ប៉ុន្តែនៅពេលជម្លោះបានចាប់ផ្តើម គាត់បានដេញខ្ញុំចេញពីផ្ទះ ហើយនិយាយថា ផ្ទះ ដី និងកូនជារបស់គាត់ទាំងអស់។

ឥឡូវ យើងរស់នៅក្នុងផ្ទះដដែលម្តងទៀត ប៉ុន្តែខ្ញុំបាននិយាយទៅកាន់មេភូមិអំពីរឿងលែងលះ។ មេភូមិបាននិយាយថា វាមិនល្អទេក្នុងការលែងលះ ប៉ុន្តែប្រសិនបើយើងចង់ ទ្រព្យសម្បត្តិនឹងត្រូវបែងចែក។ ប្រសិនបើខ្ញុំលែងលះ ខ្ញុំមិនដឹងថាខ្ញុំនឹងទៅទីណាទេ ហើយមិនដឹងថាតើកូនរបស់ខ្ញុំនឹងទៅជាមួយខ្ញុំដែរឬទេ។

ឥឡូវខ្ញុំមិនខ្លាចក្នុងការចូលរួមជាមួយអ្នកភូមិផ្សេងទៀត និងយុទ្ធនាការទប់ទល់នឹងអាជ្ញាធរនោះទេ។ ខ្ញុំដឹងថាស្វាមីរបស់ខ្ញុំខុស ប៉ុន្តែខ្ញុំមិនហ៊ានជាមួយគាត់ទេហើយក៏មិនហ៊ានប្រឆាំងនឹងគាត់ដែរ។

សកម្មជនដីធ្លីនៅជនបទ

ចែកផ្លូវពីស្វាមីរបស់អ្នកទាំងនោះ ទោះជាមាន ម្នាក់ទើបតែចាប់ផ្តើមរស់នៅជាមួយស្វាមីរបស់គាត់វិញ បន្ទាប់ពីមិត្តភ័ក្រ្តម្នាក់ជួយសម្រុះសម្រួលអ្នកទាំងពីរ។ ចំពោះស្រ្តីទី៥ ដែលមិនមែនជាអ្នកដឹកនាំសហគមន៍ ប៉ុន្តែនាងតែងតែចូលរួមក្នុងការតវ៉ា គឺនាងមិនធ្លាប់ដែលបែកចេញពីស្វាមីរបស់នាងទេ។ ស្រ្តីរូបនេះបានអធិប្បាយថាថ្មីៗនេះអំពើហិង្សាបានអន់ថយ ដោយសារតែនាងបានកាត់បន្ថយការចូលរួមក្នុងសកម្មភាពរបស់យុទ្ធនាការ ពីព្រោះសហគមន៍បានទទួលជោគជ័យក្នុងការទាមទារដីធ្លីរបស់ខ្លួនមកវិញមួយចំនួនហើយ។

នៅក្នុង ៦ករណី ផ្សេងទៀត អ្នកទាំងនោះបាននិយាយថាពួកគាត់បានឆ្លងកាត់បទពិសោធន៍អំពើហិង្សាឃោរឃៅដោយស្នាដៃស្វាមីអ្នកទាំងនោះ។ ប៉ុន្តែវាមានការពិបាកក្នុងការកត់សម្គាល់ហេតុផលនៃទំនាក់ទំនងហេតុផលរវាងអំពើហិង្សា និងភាពសកម្មនិយមរបស់អ្នកទាំងនោះ ពីព្រោះអំពើហិង្សាទាំងនេះកើតមានឡើងមុនវិវាទដីធ្លីទៅទៀត។ ស្រ្តី ៣នាក់ បានអធិប្បាយថាអំពើហិង្សាចាប់ផ្តើមក្នុងអំឡុងពេលពួកគាត់មានគត៌លើកដំបូងឬភ្លាមៗបន្ទាប់ពីកូនដំបូងរបស់អ្នកទាំងនោះបានចាប់កំណើត។ ប៉ុន្តែស្រ្តីទាំង ៦នាក់បាននិយាយថាអំពើហិង្សាកាន់តែធ្ងន់ធ្ងរឡើងចាប់តាំងពីពេលដែលវិវាទដីធ្លីចាប់ផ្តើម។ ស្រ្តី ៤នាក់ បាននិយាយថាស្វាមីអ្នកទាំងនោះក៏បានប្រើអំពើហិង្សាទៅលើកូនរបស់អ្នកទាំងនោះផងដែរ។ ស្រ្តីទាំងនេះបានពាក់ព័ន្ធនៅក្នុងវិវាទដីធ្លីអស់រយៈពេលជាច្រើនឆ្នាំ ហើយពួកគាត់បាននិយាយថា ភាពតានតឹង និងអំពើហិង្សានៅក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរឡើងៗ នៅពេលដែលវិវាទដីធ្លីបន្តកាន់តែយូរទៅៗ។ ស្វាមីអ្នកទាំងនោះកាន់តែអាក់អន់ចិត្តខ្លាំងឡើងៗ ចំពោះរយៈពេលដែលពួកគាត់ចំណាយនៅខាងក្រៅផ្ទះ ដោយសារស្វាមីរបស់ពួកគាត់បានបាត់បង់ក្តីសង្ឃឹមក្នុងការសម្រេចនូវលទ្ធផលដ៏ជោគជ័យមួយក្នុងជម្លោះដីធ្លី។ ដូច្នេះគាត់បានចោទប្រកាន់ភរិយារបស់គាត់ថាលែងខ្វល់ខ្វាយពីគ្រួសារ។ ស្រ្តីទាំងអស់បានបង្ហាញថាជម្រើសរបស់អ្នកទាំងនោះក្នុងការបន្តយុទ្ធនាការ គឺជាគន្លឹះមួយដែលនាំអោយស្វាមីរបស់អ្នកទាំងនោះប្រើអំពើហិង្សា។

ចំពោះករណីផ្សេងៗទៀត ភាពតានតឹងរវាងស្វាមី និងភរិយាដែលបង្កឡើងដោយការផ្លាស់ប្តូរនៃតួនាទីរបស់ភរិយា មិនបាននាំមកនូវអំពើហិង្សា ឬការបែកបាក់ទំនាក់ទំនងពួកគាត់ឡើយ។ ស្រ្តីមួយចំនួនបាននិយាយថាវាមានភាពតានតឹងនៅពេលដែលពួកគាត់ចាប់ផ្តើមភាពសកម្មនិយមរបស់គាត់ ពីព្រោះប្តីរបស់គាត់មិនសប្បាយចិត្តជាមួយនិងតួនាទីថ្មីរបស់គាត់ ហើយគិតថាគាត់មិនបានមើលថែរក្សាក្រុមគ្រួសារដូចដែលគាត់គួរធ្វើ។ ក៏ប៉ុន្តែ ក្រោយពេលវេលាកន្លងផុតយូរទៅ ស្វាមីអ្នកទាំងនោះបានប្រែប្រួលទៅតាមបការផ្លាស់ប្តូរនេះ ហើយបច្ចុប្បន្នស្វាមីពួកគាត់ថែមទាំងគាំទ្រការងាររបស់ពួកគាត់ និងយល់ឃើញថាអ្វីដែលពួកគាត់កំពុងធ្វើ គឺដើម្បីផលប្រយោជន៍គ្រួសារ។ នៅក្នុងករណីមួយ បន្ទាប់ពីកើតមានភាពតានតឹងខ្លះៗនៅពេលវិវាទដីធ្លីចាប់ផ្តើម ប្តីនិងភរិយាបានផ្លាស់ប្តូរតួនាទីគ្នាទាំងស្រុង ដោយភាគច្រើនប្តីធ្វើការងារមើលថែទាំកូន និងមើលថែរក្សាផ្ទះសំបែង ខណៈពេលដែលភរិយារបស់ខ្លួនធ្វើការងាររបស់នាងក្នុងនាមជាអ្នកដឹកនាំសហគមន៍ និងអ្នកធ្វើយុទ្ធនាការ។ ស្រ្តីម្នាក់នេះបានទទួលស្គាល់ថាភាពតានតឹងនៅតែមាន ហើយនាងមិនដឹងថាអនាគតនឹងទៅជាយ៉ាងណានោះទេ។ នាងមានអារម្មណ៍ថា ដរាបណាជម្លោះបន្តកាន់តែបន្តយូរទៅ ឱកាសដែលទំនាក់ទំនងរវាងនាងនិងស្វាមីរបស់នាង មានភាពកាន់តែពិបាកទៅៗ។

នៅក្នុងសហគមន៍ជនបទមួយ វាមានលក្ខណៈធម្មតាដែលបុរស និងស្រ្តីចូលរួមក្នុងយុទ្ធនាការ ហើយចំពោះប្តី និងភរិយា គឺពួកគាត់ចូលរួមការតវ៉ាទាំងអស់គ្នា ឬពួកគាត់ចែកវេនគ្នាដើម្បីចូលរួម ដោយទុកម្នាក់អោយនៅផ្ទះដើម្បីមើលថែកូន។ ចំពោះគ្រួសារដែលរៀបចំខ្លួនពួកគាត់បែបនេះ ថ្វីបើវានៅតែមានភាពតានតឹងកើតមានឡើងដោយសារការគំរាមកំហែងនៃការបាត់បង់ដីធ្លីក៏ដោយ ក៏ភាពតានតឹងដែលជាលទ្ធផលនៃការចូលរួមរបស់ស្រ្តីនៅក្នុងយុទ្ធនាការ គឺមានតិចតួច។

ស្រ្តីជាច្រើនបានទទួលស្គាល់ថា ស្វាមីអ្នកទាំងនោះមានហេតុផលសមស្របខ្លះៗសំរាប់ជំទាស់នឹងសកម្មភាពយុទ្ធនាការរបស់អ្នកទាំងនោះ។ ខណៈដែលអ្នកទាំងនោះយល់ថាការរិះគន់ពីស្វាមីពួកគាត់ជាញឹកញាប់មិនយុត្តិធម៌ និងមានសម្ពាធដ៏ធ្ងន់ទៅលើរូបគាត់ វាក៏មានពេលខ្លះ ដែរដែលគាត់គិតថាការរិះគន់ទាំងនោះគឺសមហេតុផល។ ពួកគាត់បានរៀបរាប់ថាប្តីពួកគាត់ជាញឹកញាប់តែងតែនិយាយថាគាត់មិនជំទាស់និងភរិយាគាត់ចូលរួមក្នុងយុទ្ធនាការនោះទេ ដរាបណាដែលភរិយាគាត់មិនមែនជាអ្នកដឹកនាំ និងមិនឈរនៅជួរមុខនៅពេលធ្វើការតវ៉ា។ នេះកើតឡើង

## ករណីសិក្សា

នៅមុនពេលមានជម្លោះ ជីវិតគឺសប្បាយ យើងមានជីវភាពរស់នៅសមរម្យ។ ស្វាមីរបស់ខ្ញុំមានការងារធ្វើ ហើយខ្ញុំមានពេលវេលាមើលថែរក្សាក្រុមគ្រួសារ ប៉ុន្តែក្រោយមក ខ្ញុំត្រូវការចំណាយពេលច្រើនលើការធ្វើយុទ្ធនាការ។ ដូចនេះខ្ញុំបានកាត់បន្ថយពេលវេលានៅផ្ទះ។

ជម្លោះបានកើតឡើង លើក្រុមគ្រួសារជាច្រើន។ គ្រួសារមួយចំនួននៅល្អនឹងគ្នា ប៉ុន្តែមានការឈ្លោះគ្នា និងភាពតានតឹងជាច្រើន ទោះបីជាទំនាក់ទំនងមិនបែកបាក់ ព្រោះស្រ្តីមិនមានពេលសម្រាប់ធ្វើម្ហូប និងមើលថែរក្សាកូន។

ព្រោះតែយុទ្ធនាការ ខ្ញុំមិនបានចំណាយពេលជាមួយក្រុមគ្រួសារខ្ញុំទេ ហើយស្វាមីរបស់ខ្ញុំបានខឹង និងប្រាប់ខ្ញុំឲ្យឈប់ ប៉ុន្តែវាលំបាកក្នុងការលាឈប់ ព្រោះសមាជិកសហគមន៍មួយចំនួន មិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី នៅឡើយ ដូចនេះខ្ញុំមិនអាចឈប់បានទេ។ គាត់ខឹងនឹងខ្ញុំយ៉ាងខ្លាំង រហូតដល់មានអំពើហិង្សាផ្លូវកាយ។មុនពេលមានយុទ្ធនាការ គាត់មិនដែលជេរខ្ញុំទេ។ ជាធម្មតានៅពេល ខ្ញុំទៅធ្វើយុទ្ធនាការគាត់ជេរខ្ញុំ ហើយប្រាប់ខ្ញុំឲ្យឈប់ហើយគាត់បានប្រើហិង្សា។ គាត់មិនយល់ពីខ្ញុំទេ។ អ្នកដឹកនាំសហគមន៍បានព្យាយាមសម្របសម្រួល ពួកយើង ប៉ុន្តែវាអត់ប្រយោជន៍ ព្រោះស្វាមីរបស់ខ្ញុំបានឲ្យជម្រើសខ្ញុំពីរ ឈប់ធ្វើយុទ្ធនាការ ឬមិនឈប់។ ខ្ញុំជ្រើសរើសយកសហគមន៍។

នៅពេលយើងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ស្វាមីរបស់ខ្ញុំចង់លែងលះ។ ដូចនេះយើងក៏លែងលះ ហើយបែងចែកផ្ទះជាពីរ។ ខ្ញុំយកចំណែករបស់ខ្ញុំធ្វើបន្ទប់ជួល ហើយប្រើប្រាស់លុយដើម្បីជួយផ្គត់ផ្គង់ការអប់រំរបស់កូន។

ខ្ញុំបានធ្វើយុទ្ធនាការដើម្បីដីធ្លីសម្រាប់កូនរបស់ខ្ញុំ ព្រោះខ្ញុំឃើញសហគមន៍ផ្សេងៗទៀតនៅតំបន់តាំងទីលំនៅថ្មី ខ្ញុំបានឃើញពីជីវភាពរស់នៅរបស់ពួកគេ។ ពួកគេរស់នៅលំបាកណាស់។ កូនៗមិនបានស្លៀកពាក់សមរម្យ ហើយដូចជាស្លាប់អញ្ចឹង។ ខ្ញុំគិតថាស្លាប់នៅទីនេះល្អជាងផ្លាស់ទីលំនៅទៅទីនោះ ដូចនេះខ្ញុំបន្តតស៊ូ។

ប៉ុន្តែការធ្វើយុទ្ធនាការ បានជះឥទ្ធិពលដល់កូនៗផងដែរ។ ខ្ញុំព្រួយបារម្ភ ព្រោះឥឡូវកូននៅក្មេង ហើយការអប់រំគេមិនទាន់ចំណាយច្រើន ប៉ុន្តែនៅពេលពួកគេធំឡើង ការអប់រំនឹងត្រូវចំណាយច្រើន។

សកម្មជនដីធ្លីនៅទីក្រុង

ចេញមកពីការភ័យខ្លាចដែលភរិយារបស់អ្នកទាំងនោះអាចនឹងរងរបួស ឬត្រូវបានចាប់ខ្លួន។ យោងតាមប្រវត្តិសាស្ត្រនៃវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា ការភ័យខ្លាចទាំងនេះគឺសមហេតុសមផលណាស់។ ស្ត្រីទាំងនេះក៏បាននិយាយដែរថា ការខ្វល់ខ្វាយរបស់ប្តីពួកគាត់ចំពោះការថយចុះនៃការយកចិត្តទុកដាក់របស់អ្នកទាំងនោះចំពោះការថែទាំកូន និងហិរញ្ញវត្ថុគ្រួសារ គឺមិនមែនមិនសមហេតុផលទាំងស្រុងនោះទេ។ អ្នកទាំងនោះបានឃើញថាវាបានដាក់បន្ទុកទៅលើស្វាមីពួកគាត់ធ្ងន់ធ្ងរជាងមុនទៅទៀត ហើយវាគឺជាប្រពភដ៏ពិតប្រាកដមួយនៃភាពតានតឹងផ្នែកអារម្មណ៍ (ស្ត្រេស/STRESS) ចំពោះពួកគាត់។ ស្ត្រី ២នាក់បានអធិប្បាយថាស្វាមីអ្នកទាំងនោះធ្វើការងារនៅយោធា ដូច្នេះពួកគាត់ព្រួយបារម្ភថាស្វាមី អ្នកទាំងនោះអាចត្រូវបាគេរើសអើងនៅកន្លែងការងាររបស់គាត់ ដោយសារតែភាពសកម្មនិយមរបស់ភរិយាគាត់។ស្ត្រីទាំង២នាក់បានទទួលស្គាល់ថាមូលហេតុនេះគឺជាការព្រួយបារម្ភដ៏ត្រឹមត្រូវមួយ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ដើម្បីបញ្ចុះបញ្ចូលគាត់អោយបញ្ឈប់ភាពសកម្មនិយមរបស់អ្នកទាំងនោះ។

## ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច

នៅក្នុងករណីនៃស្ត្រីទាំងអស់ដែលចូលរួមបទសម្ភាសន៍ វិវាទដីធ្លី និងការចូលរួមរបស់ពួកគាត់នៅក្នុងយុទ្ធនាការបានធ្វើអោយមានផលប៉ះពាល់សេដ្ឋកិច្ច ដែលនៅក្នុងករណីខ្លះគឺមានភាពធ្ងន់ធ្ងរ។ នៅសហគមន៍នៅក្នុងទីក្រុង ស្ត្រីរងទុក្ខដោយការថយចុះនៃប្រាក់ចំណូល ដែលជាលទ្ធផលនៃកត្តាចំបងពីរ។ កត្តាទី១ គឺមុនពេលមានវិវាទដីធ្លី ស្ត្រីជាច្រើននាក់បានប្រើប្រាស់ផ្ទះរបស់ខ្លួនដើម្បីបង្កើតចំណូល ដោយយកបន្ទប់ ១ ឬ ២ ធ្វើជាហាងកាហ្វេ ឬហាងលក់ឥវ៉ាន់តូចមួយ ឬក៏ជួលបន្ទប់នោះអោយទៅភ្ញៀវស្នាក់នៅ។ ដូច្នេះអ្នកដែលបាត់បង់ផ្ទះរបស់ខ្លួន គឺក្នុងពេលជាមួយគ្នាក៏បាត់បង់ប្រភពចំណូលដ៏សំខាន់មួយផងដែរ។ អ្នកឯទៀតបន្តនៅក្នុងផ្ទះរបស់អ្នកទាំងនោះ ប៉ុន្តែបានឃើញថាមុខជំនួញរបស់ពួកគាត់មិនអាចបន្តដំណើរការទៀតបាន ដែលនេះជាលទ្ធផលនៃការបណ្តេញចេញពីផ្ទះសំបែងជុំវិញអ្នកទាំងនោះ និងការបំផ្លិចបំផ្លាញនៃសហគមន៍របស់ពួកគាត់។ កត្តាចំបងទី ២ នៃការបាត់បង់ចំណូល គឺជាការចូលរួមរបស់ស្ត្រីនៅក្នុងយុទ្ធនាការ។ មុនពេលមានវិវាទដីធ្លី ស្ត្រីជាច្រើនមានការងារជា អ្នកលក់ ឬអ្នកសំអាតនៅផ្សារ។ ប៉ុន្តែដោយសារតែយុទ្ធនាការរបស់ពួកគាត់ ដែល រួមមានការប្រជុំទៀងទាត់ ការតវ៉ាតាម ដងផ្លូវ ហើយសំរាប់ស្ត្រីខ្លះ គឺគាត់ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ដូច្នេះគាត់មិនអាចបន្តធ្វើការងារអោយបានទៀងទាត់ទៀតឡើយ។

> "ស្វាមីរបស់ខ្ញុំនឹងខឹង ប្រសិនបើខ្ញុំទៅធ្វើយុទ្ធនាការ ព្រោះវាចំណាយលុយក្នុងការធ្វើដំណើរ ហើយពួកយើងកំពុងជាប់ បំណុល និងមានកូនច្រើនផង។"
>
> សកម្មជនដីធ្លីនៅជនបទ

នៅក្នុងសហគមន៍នៅជនបទ ឥទ្ធិពលនៃការធ្វើយុទ្ធនាការ គឺមានការកត់សម្គាល់តិចតួច ដោយសារស្ត្រីចូលរួមក្នុងបទសម្ភាសន៍ ជាច្រើននាក់ គឺមិនទៅធ្វើការងារទេ ប៉ុន្តែដោយឡែកពួកគាត់ធ្វើការលើដីរបស់ពួកគាត់។ ពួកគាត់និយាយថា ចំណូលរបស់ពួកគាត់បានធ្លាក់ចុះ ដោយសារពួកគាត់ឈប់សម្រាកប៉ុន្មានថ្ងៃ ដើម្បី ចូលរួមការតវ៉ា ប៉ុន្តែដោយសារតែពួកគាត់មិនបាន បាត់បង់ការងាររបស់គាត់ ដូច្នេះការថយចុះនៃប្រាក់ចំណូល គឺមិនមានភាពធ្ងន់ធ្ងរ ដូចនៅសហគមន៍ក្នុងទីក្រុងនោះទេ។ទោះជាយ៉ាងណាក៏ដោយ សហគមន៍ជនបទគឺមានភាពក្រីក្រខ្លាំងជាងសហគមន៍នៅទីក្រុង មុនវិវាទដីធ្លីរបស់ពួកគាត់ ចាប់ផ្តើមទៅទៀត ដោយគ្រួសារជាច្រើនរស់នៅក្នុងជីវភាពដែលត្រឹមតែរស់រួចមួយថ្ងៃៗ។

ការបាត់បង់ប្រាក់ចំណូល មានផលប៉ះពាល់មួយចំនួនទៅលើស្ត្រីដែលចូលរួមក្នុងបទសម្ភាសន៍ និងគ្រួសាររបស់ពួកគាត់។ មុនពេលដែលវិវាទកើតឡើង មិនមានស្ត្រីណាម្នាក់មានទ្រព្យសម្បត្តិស្តុកស្តម ប៉ុន្តែស្ត្រីភាគច្រើនអាចដោះស្រាយប្រាក់ចំណាយសំរាប់ជីវភាពរស់នៅ ហើយអាចផ្តល់អោយកូនរបស់ពួកគាត់បាន។ ស្ត្រីខ្លះបានកំពុងតែរស់នៅលើខ្សែបន្ទាត់ក្រីក្រតែបន្តិចប៉ុណ្ណោះ។ ដូច្នេះការធ្លាក់ចុះនៃប្រាក់ចំណូល គឺមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើពួកគាត់។
ស្ត្រីខ្លះបាននិយាយថា បច្ចុប្បន្ននេះពួកគាត់រកបានប្រាក់តិចតួចដោយធ្វើការងារដែលពួកគាត់មិនសូវពេញចិត្ត ឧទាហរណ៍ដូចជាការប្រមូលសំរាម ដែលជាសកម្មភាពមួយដែលកូនរបស់ពួកគាត់ក៏បានចូលរួមផងដែរ។ ស្ត្រីជាច្រើននាក់បាននិយាយថាដើម្បីបន្តមានជីវិតបាន ពួកគាត់ត្រូវខ្ចីប្រាក់ពី

### ករណីសិក្សា

ការធ្វើយុទ្ធនាការ បានបង្កជាបញ្ហាជាច្រើននៅក្នុងគ្រួសាររបស់ខ្ញុំ ព្រោះវាចំណាយពេលច្រើនថ្ងៃ និងត្រូវចំណាយប្រាក់កាស ហើយខ្ញុំមានកូន ៥នាក់។ ស្វាមីរបស់ខ្ញុំនឹងខឹង ប្រសិនបើខ្ញុំទៅធ្វើយុទ្ធនាការ ព្រោះវាចំណាយលុយក្នុងការធ្វើដំណើរ ហើយពួកយើងកំពុងជាប់បំណុល និងមានកូនច្រើនផង។ គាត់ជេរខ្ញុំ ហើយវាយដំខ្ញុំជាច្រើនដង។ គាត់វាយដំកូនៗថែមទៀតផង។ អំពើហិង្សាបានកើតឡើងនៅមុនពេលមានជម្លោះដីធ្លី។ វាចាប់ផ្តើមកើតឡើង នៅពេលខ្ញុំមានផ្ទៃពោះជាលើកដំបូង ប៉ុន្តែបន្ទាប់ពីមានជម្លោះដីធ្លី អំពើហិង្សាបានកើនឡើង។

នៅពេលគាត់ប្រើអំពើហិង្សា ជាទូទៅខ្ញុំគេចចេញទៅផ្ទះអ្នកជិតខាង។ មានតែពេលដែលខ្ញុំត្រូវបានគាត់វាយដំធ្ងន់ធ្ងរ ទើបខ្ញុំទៅផ្ទះគ្រួសារខ្ញុំ។ ខ្ញុំមិនដែលប្តឹងនគរបាល អាជ្ញាធរក្នុងតំបន់ ឬអង្គការមិនមែនរដ្ឋាភិបាលឲ្យជួយខ្ញុំទេ ដោយជាទូទៅគឺពឹងតែអ្នកជិតខាង។ ខ្ញុំបានរាយការណ៍វាទៅមេភូមិ។ គាត់បាននិយាយថានេះជារឿងក្នុងគ្រួសារ ដូចនេះគាត់មិនជ្រៀតជ្រែកនោះទេ។ គាត់បានប្រាប់ខ្ញុំ៖ "វាជារឿងផ្ទៃក្នុង អ្នកនឹងត្រូវគ្នាវិញនៅថ្ងៃស្អែក"។

នៅពេលនោះ ខ្ញុំកំពុងស្នាក់នៅជាមួយម្តាយរបស់ខ្ញុំ និងកូនទាំងអស់ ហើយខ្ញុំភ័យខ្លាច មិនហ៊ានត្រលប់ទៅផ្ទះទេ ប្រសិនបើគាត់នៅតែខឹង។ ខ្ញុំត្រូវការឪពុកម្តាយខ្ញុំ ដើម្បីនិយាយជាមួយគាត់ ដូចនេះ ខ្ញុំអាចត្រលប់ទៅផ្ទះវិញដោយសុវត្ថិភាព។

នៅពេលខ្ញុំទៅធ្វើយុទ្ធនាការ ហើយ ឃើញពលរដ្ឋក្លាហានជាច្រើន ខ្ញុំមានជំនឿចិត្ត ប៉ុន្តែជាមួយស្វាមីរបស់ខ្ញុំ ខ្ញុំនៅតែមិនហ៊ានទុកចិត្ត។

សកម្មជនដីធ្លីនៅជនបទ

អ្នកចង់ការប្រាក់ក្រៅផ្លូវការ ហើយឥឡូវនេះពួកគាត់មានបំណុលដ៏ច្រើនដែលពួកគាត់គ្មានផ្លូវដើម្បីសងវា។ ស្រ្តី ២ ឬ ៣ នាក់បាននិយាយថាគាត់ស្គាល់អ្នកដទៃទៀតដែលបានធ្វើជាស្រ្តីពេស្យាដើម្បីរកប្រាក់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមិនមានស្រ្តីណាម្នាក់ចូលរួមក្នុងបទសម្ភាសន៍បាននិយាយថាពួកគាត់ធ្លាប់បានធ្វើបែបនេះនោះទេ។

ស្រ្តីទាំងអស់បាននិយាយថា ឥទ្ធិពលនៃការបាត់បង់ប្រាក់ចំណូលទៅលើកូនរបស់អ្នកទាំងនោះ ជាពិសេសនៅពេលដែលអ្នកទាំងនោះមិនអាចទ្រទ្រង់ការបង់ថ្លៃសាលារៀនកូនៗរបស់ពួកគេបាន ហើយក្នុងករណីមិនមានលទ្ធភាពទិញថ្នាំសំខាន់ៗបាន។ ឥទ្ធិពលនេះ ជាប្រភពនៃជម្លោះផ្ទៃខាងក្នុងសម្រាប់ស្រ្តីទាំងអស់ ដោយសារមូលហេតុចំបងរបស់អ្នកទាំងនោះក្នុងការចាប់តួនាទីជាអ្នកធ្វើយុទ្ធនាការ គឺដើម្បីផ្តល់នូវជីវិតដ៏ល្អមួយសម្រាប់កូនរបស់អ្នកទាំងនោះ ដោយធានាថាពួកគេមានផ្ទះសម្បែងនាពេលឥឡូវ និងពេលអនាគត។ ពួកគេទាំងអស់ទទួលស្គាល់ថាដោយសារលទ្ធផលនៃជម្រើសនេះ ពួកគេត្រូវលះបង់ទំហំជាក់លាក់មួយនៃការថែរក្សា និងអប់រំកូនៗរបស់ពួកគេ។ ដូចនេះអ្នកទាំងនោះមានអារម្មណ៍ថាទោះជាពួកគេមានគោលបំណងល្អយ៉ាងណា ក៏សកម្មភាពរបស់អ្នកទាំងនោះបានប៉ះពាល់ដល់អនាគតរបស់កូនៗអ្នកទាំងនោះដដែល។


ពលរដ្ឋនៃតំបន់បណ្តេញចេញបុរីកីឡា ក្នុងរាជធានីភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០១៤

ការបាត់បង់ប្រាក់ចំណូល គឺជាមូលហេតុដ៏សំខាន់មួយដែលបង្កើតឲ្យមានភាពតានតឹងរវាងស្វាមី និងភរិយា ហើយជានិច្ចជាកាលវានាំអោយឈានទៅដល់ការឈ្លោះប្រកែកគ្នា។ នៅពេលដែលស្រ្តីរស់នៅជាមួយគ្រួសារសាច់ញាតិ ការថយចុះនៃជំនួយរបស់ពួកគាត់ចំពោះថវិកាគ្រួសារទាំងមូល ក៏ជាបញ្ហាផងដែរ។ នៅក្នុងករណីទាំងពីរ ស្រ្តីត្រូវបានរិះគន់ចំពោះការបន្តធ្វើយុទ្ធនាការរបស់ពួកគាត់ ហើយពួកគាត់ត្រូវបានរងសម្ពាធឲ្យលះបង់ភាពសកម្មនិយមរបស់ពួកគាត់ដើម្បីអោយពួកគាត់អាចរកប្រភពចំណូលទៀងទាត់មួយ។ ចំពោះករណីដែលមានអំពើហិង្សាកើតឡើង ស្រ្តីបាននិយាយថាវិបត្តិហិរញ្ញវត្ថុ និងជាពិសេសបំណុលដែលមានស្រាប់ គឺជាកត្តាដ៏សំខាន់មួយដែលជួយបង្កអោយមានការឈ្លោះប្រកែកគ្នាកើតឡើង។

ការបាត់បង់ចំណូលក៏បាននាំអោយឈានទៅដល់ការបែកបាក់គ្រួសារ នៅក្នុងគ្រួសារដែលគ្មានអំពើហិង្សាកើតឡើងផងដែរ។ ស្រ្តី 3 ឬ 4 នាក់បាននិយាយថាប្តី ហើយនិងកូនពេញវ័យរបស់ពួកគាត់បានចាកចេញពីគាត់ដើម្បីទៅរកការងារធ្វើនៅឯខេត្តដទៃទៀត ឬនៅប្រទេសថៃ។ ចំពោះករណីខ្លះ អ្នកទាំងនោះដែលបានផ្លាស់ទីលំនៅដើម្បីការងារបានផ្ញើរប្រាក់មកផ្ទះ ប៉ុន្តែចំពោះករណីខ្លះ ស្រ្តីមិនបានលឺដំណឹងអ្វីសោះ ហើយនិយាយថាគាត់មិនរំពឹងថានឹងឃើញសមាជិកគ្រួសាររបស់ពួកគាត់ទៀតទេ។

## ករណីសិក្សា

ចាប់តាំងពីចូលរួមក្នុងយុទ្ធនាការ ពេលវេលាជាមួយកូនរបស់ខ្ញុំ ត្រូវបានកាត់បន្ថយប្រហែល ៧០ ភាគរយ។ ខ្ញុំកម្របានជួយពួកគេណាស់ គឺមានតែចុងសប្តាហ៍ប៉ុណ្ណោះ ដូចនេះពួកគេត្រូវចេះមើលថែរក្សាខ្លួនឯង ហើយរកអាហារដោយខ្លួនឯង។ នៅពេលខ្ញុំត្រូវបានគេចាប់ខ្លួន ខ្ញុំបាត់បង់ការងារធ្វើ និងស្វាមីរបស់ខ្ញុំក៏បាត់បង់ការងារផងដែរ ព្រោះក្រុមហ៊ុនរលំ។ដោយសារហេតុនេះហើយកូនរបស់ខ្ញុំត្រូវពឹងលើបងប្អូនរបស់ខ្ញុំ។ ពួកគេមិនសូវសប្បាយចិត្តជាមួយខ្ញុំទេ ព្រោះខ្ញុំមិនមានការងារធ្វើ ហើយស្វាមីរបស់ខ្ញុំមិនសប្បាយចិត្តនឹងខ្ញុំ ព្រោះខ្ញុំមិនមានពេលមើលថែកូន។ ទោះបីជាអ្នកជិតខាងរិះគន់ខ្ញុំ ហើយបាននិយាយថាខ្ញុំទៅធ្វើយុទ្ធនាការ នោះដោយសារខ្ញុំចង់ល្បីឈ្មោះប៉ុណ្ណោះទេ។ បងប្អូនខ្ញុំ បានប្រាប់ខ្ញុំឲ្យមើលថែរក្សាកូនដោយខ្លួនឯង ហើយយកពួកវាទៅសាលារៀន ដូចនេះ ឥឡូវខ្ញុំបានលក់អ្វីៗរបស់ខ្ញុំ ដើម្បីយកប្រាក់បង់ថ្លៃសាលារៀនរបស់ពួកគេ។

ឥឡូវ ខ្ញុំហត់នឿយ ហើយមិនដឹងពីវាសនារបស់ក្រុមគ្រួសាររបស់ខ្ញុំទេ ហើយខ្ញុំ មិនដឹងថាអ្នកណាជាអ្នកមើលថែរក្សាកូនរបស់ខ្ញុំទៅថ្ងៃអនាគតនោះទេ។ និយាយដោយត្រង់ ខ្ញុំចង់ឈប់ធ្វើយុទ្ធនាការ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាសហគមន៍ត្រូវបានគេធ្វើបាប ហើយវាធ្វើឲ្យខ្ញុំពិបាកចិត្ត ដូចនេះខ្ញុំក៏បន្តសកម្មភាព។ ខ្ញុំក៏ចង់ជួយសង្គម និងធ្វើការដើម្បីពង្រឹងសហគមន៍ផ្សេងទៀត ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំមានកំលាំងដែរឬទេ។ កំលាំងរបស់ខ្ញុំកំពុងអស់ហើយ ហើយខ្ញុំព្រួយបារម្ភណាស់។ ថ្មីៗនេះ ខ្ញុំមានអារម្មណ៍បាក់ទឹកចិត្តយ៉ាងខ្លាំង។ ខ្ញុំចង់ចូលក្នុងបន្ទប់ និងទទួលទានដំណេកតែប៉ុណ្ណោះ។

ពីមុន ខ្ញុំគ្រាន់តែជាអ្នកលក់អាហារ ដូចនេះខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងណាពេលមានបញ្ហានោះទេ។ ឥឡូវខ្ញុំដឹងថាតើគួរទៅសាលាក្រុង ឬក្រសួង ឬស្ថាប័នណាមួយ។ដូចនេះឥឡូវ ខ្ញុំមានជំនឿចិត្តច្រើន និងយល់ដឹងច្រើនអំពីតួនាទី និងការទទួលខុសត្រូវរបស់នគរបាល ហើយខ្ញុំអាចអនុវត្តសិទ្ធិរបស់ខ្ញុំបានល្អជាងមុន។ ប៉ុន្តែចំនុចអវិជ្ជមាន គឺខ្ញុំកាន់តែឆាប់ឆេវឆាវឡើងៗ ខ្ញុំឆាប់ខឹង។

ខ្ញុំមានកូន បីនាក់។ ឥឡូវពួកគេមានអាយុ ២០ឆ្នាំ ១៦ឆ្នាំ និង១០ឆ្នាំ។ កូនពៅព្រួយបារម្ភ និងប្រាប់ខ្ញុំថា គាត់មិនចង់ឲ្យខ្ញុំត្រូវ

## ផលប៉ះពាល់ផ្នែកសតិអារម្មណ៍

ស្ត្រីទាំងអស់បាននិយាយថាការធ្វើយុទ្ធនាការអស់រយៈពេលជាច្រើនឆ្នាំ ការមន្ទិលសង្ស័យមិនដឹងថាអ្វីនឹងកើតឡើងទៅលើពួកគាត់ និងភាពតានតឹងក្នុងគ្រួសារ បានដាក់ទម្ងន់យ៉ាងធ្ងន់ធ្ងរទៅលើសតិអារម្មណ៍របស់ពួកគាត់។ ស្ត្រីច្រើននាក់បានពិពណ៌នាអំពីរោគសញ្ញានៃជំងឺតានតឹងផ្នែកអារម្មណ៍ (ស្ត្រេស/STRESS) ឬជំងឺបាក់ទឹកចិត្ត ដូចជាការមិនងងុយដេក ឬអ្វីដែលខ្លាំងបំផុត គឺការចង់នៅផ្ទះ និងទទួលទានដំណេកពេញមួយថ្ងៃ។ ស្ត្រីមួយចំនួនបាននិយាយថាជាញឹកញាប់ពួកគាត់តែងតែមានការប្រែប្រួលអារម្មណ៍យ៉ាងរហ័ស និងខ្លាំងក្លា ដូចជាអារម្មណ៍សោកសៅយ៉ាងខ្លាំង ដែលបន្តដោយអារម្មណ៍សប្បាយរីករាយ។ ស្ត្រីស្ទើរតែទាំងអស់បាននិយាយថាពួកគាត់ឥឡូវនេះឆាប់ឆេវឆាវច្រើនជាងពេលមុន។ មានន័យថាជម្លោះបន្តិចបន្តួចតែងតែបញ្ចប់ដោយការឈ្លោះប្រកែកដែលមិនចាំបាច់។ ស្ត្រី ៣នាក់ បាននិយាយថា ពួកគាត់បានធ្លាប់គិតពីការធ្វើអត្តឃាតជាច្រើនលើកក្នុងកំឡុងរយៈពេលប៉ុន្មាន ឆ្នាំនេះ។ ស្ត្រីមួយចំនួនបាននិយាយថា ពួកគាត់ជឿជាក់ថាអារម្មណ៍ដ៏ពិបាកទាំងនេះ នឹងរសាយបាត់ប្រសិនបើវិវាទដីធ្លីត្រូវបានដោះស្រាយ។ ចំណែកឯស្ត្រីដ៏ទៃទៀត បាននិយាយថាពួកគាត់មានអារម្មណ៍ថាការប្រែប្រួលទាំងឡាយដែលពួកគាត់ឆ្លងកាត់ គឺមានភាពអាក្រក់យ៉ាងធ្ងន់ធ្ងរ ហើយវាទំនងជានឹងមានឥទ្ធិពលទៅលើគាត់ជារៀងរហូត។

ផលប៉ះពាល់ផ្នែកសតិអារម្មណ៍ គឺមានភាពអាក្រក់ធ្ងន់ធ្ងរចំពោះស្ត្រីដែលត្រូវបានបណ្តេញចេញពីផ្ទះរបស់ពួកគាត់ និងកំពុងរស់នៅក្រោមទីជំរកបណ្តោះអាសន្ន។ដូចគ្នាទៅនិងភាពតានតឹងដែលកើតឡើងមកពីការធ្វើជាសកម្មជន ស្ថានភាពរស់នៅខ្វះខាតរបស់ពួកគាត់ ហើយជាពិសេសកង្វះទាំងស្រុងនៃសិទ្ធិឯកជន គឺបានផ្តល់ផលពិបាកយ៉ាងខ្លាំងបំផុតដែលពួកគាត់មិនអាចទ្រាំទ្របាន។ ស្ត្រីទាំងអស់បាននិយាយអំពីការឈឺចាប់ឥតឈប់ឈរដែលបង្កឡើងដោយការមិនអាចលាងសម្អាតខ្លួន ឬមិនអាចទៅបន្ទប់ទឹកជាឯកជនបាន។ ពួកគាត់បានពិពណ៌នាពីអារម្មណ៍ទាំងអស់ដែលបានរៀបរាប់ខាងលើ ប៉ុន្តែអារម្មណ៍ទាំងនេះហាក់បីដូចជាធ្វើអោយគាត់ឈឺចាប់យ៉ាងខ្លាំងក្លាបំផុត ហើយពួកគាត់ជារឿយៗតែងតែសម្រក់ទឹកភ្នែក ឬចង់សម្រក់ទឹកភ្នែកនៅពេលដែលពួកគាត់រៀបរាប់អំពីអារម្មណ៍របស់ពួកគាត់។

### ករណីសិក្សា (ត)

បានគេចាប់ខ្លួនម្តងទៀតនោះទេ ព្រោះវាធ្វើឲ្យគាត់ពិបាកចិត្តឃើញឪពុករបស់គេចូលទទួលទានដំណេកហើយយំ។ កូនស្រីរបស់ខ្ញុំក៏បានប្រាប់ខ្ញុំដូចគ្នាដែរ។ វាពិបាកសម្រាប់ខ្ញុំ ព្រោះកូនស្រីខ្ញុំធ្លាប់ជាសិស្សពូកែ ប៉ុន្តែនៅពេលខ្ញុំចូលពន្ធនាគារ ការសិក្សារបស់គេធ្លាក់ចុះ។ វាមានឥទ្ធិពលប៉ះពាល់ដល់ខ្ញុំ ដោយកូនរបស់ខ្ញុំនឹងមិនទទួលបានការអប់រំដ៏ល្អ។ យើងជាសកម្មជន មិនមានការចេះដឹងបានខ្ពស់នោះទេ។ មនុស្សមួយចំនួនក្នុងចំណោមពួកយើង មិនអាចនឹងសរសេរអក្សរខ្មែរបានល្អនោះផង។ ខ្ញុំមិនចង់បានស្ថានភាពនេះ បន្តទៅក្មេងជំនាន់ក្រោយ ដោយសារភាពសកម្មនិយមរបស់យើងនោះទេ។

សកម្មជនដីធ្លីនៅទីក្រុង



ប្រជាពលរដ្ឋមកពីខេត្តកំពង់ស្ពឺ មកតវ៉ានៅមុខធានាគារ ANZ Royal ក្នុងរាជធានីភ្នំពេញ កាលពីខែសីហា ឆ្នាំ២០១៤

ស្ត្រីខ្លះក៏បានពិពណ៌នា ពីផលប៉ះពាល់ទៅលើរូបគាត់នៃការប៉ះទង្គិចហិង្សាជាច្រើនដង និងញឹកញាប់ជាមួយនឹងនគរបាល និងអាជ្ញាធរផ្សេងៗទៀត។ ស្ត្រីទាំងអស់ធ្លាប់មានបទពិសោធន៍យ៉ាងហោចណាស់ ជាការប្រមាថមើលងាយពីអាជ្ញាធរ នៅពេលពួកគាត់កំពុងតែធ្វើការតវ៉ា និងស្ត្រីជាច្រើននាក់បានទទួលរងអំពើហិង្សាជានិច្ចជាកាល។ ស្ត្រីម្នាក់បានបង្ហាញពីទំនាក់ទំនងរវាងអំពើហិង្សាដែលគាត់ធ្លាប់ទទួលរងដោយស្នាដៃរបស់អាជ្ញាធរ និងភាពតានតឹងរវាងគាត់ និងស្វាមីរបស់គាត់។ គាត់បាននិយាយថា ជាញឹកញាប់គាត់បានឃើញថាគាត់មានអារម្មណ៍ឆេវឆាវចំពោះស្វាមីគាត់ ហើយមានពេលមួយគាត់បានគ្រវីកំបិតដាក់ស្វាមីគាត់ទៀតផង។ គាត់និយាយថាគាត់ដឹងថាខុស ហើយគាត់មិនចង់ធ្វើបែបនោះទេ ប៉ុន្តែដោយសារការទទួលរងអំពើហិង្សាពីអាជ្ញាធរញឹកញាប់ពេក បានធ្វើអោយគាត់ក្លាយខ្លួនទៅជាមនុស្សឆេវឆាវជាងមុនដែលគ្រប់គ្រងកំហឹងខ្លួនឯងបានតិចតួច។

ថ្វីបើបែបនេះក៏ដោយ ស្ត្រីទាំងអស់មានភាពវិជ្ជមានខ្លះដើម្បីនិយាយអំពីថាតើតួនាទីរបស់គាត់ជាអ្នកធ្វើយុទ្ធនាការបានជួយដល់ការអភិវឌ្ឍន៍ខ្លួនគាត់ផ្ទាល់យ៉ាងដូចម្តេចខ្លះ។ ពួកគាត់បាននិយាយថាឥឡូវនេះពួកគាត់មានភាពគោរពតិចតួចណាស់ចំពោះអាជ្ញាធរ ហើយថ្វីបើពួកគាត់ធ្លាប់ទទួលរងអំពើហិង្សាដោយសារស្នាដៃអាជ្ញាធរក៏ដោយ ក៏ពួកគាត់មានការភ័យខ្លាចតិចតួចណាស់ចំពោះអាជ្ញាធរ។ ពួកគាត់បានពន្យល់ថា ពួកគាត់ឥឡូវនេះយល់ដឹងថាសិទ្ធិរបស់គាត់មានអ្វីខ្លះ ហើយពួកគាត់មិនខ្លាចនឹងក្រោកឈរដើម្បីសិទ្ធិរបស់គាត់នោះទេ។ ស្ត្រីជាច្រើននាក់បាននិយាយថាពួកគាត់មានមោទនភាពនឹងអ្វីដែលពួកគាត់សម្រេចបាន និងអ្វីដែលពួកគាត់បានរៀន ហើយថ្វីបើមានឧបសគ្គទាំងឡាយក៏ដោយ ក៏ពួកគាត់មានអារម្មណ៍ថាពួកបានក្លាយជាមនុស្សរឹងប៉ឹងជាងមុន ដែលនេះជាលទ្ធផលនៃការធ្វើយុទ្ធនាការរបស់ពួកគាត់។

## ការឆ្លើយតបរបស់ស្ត្រីចំពោះអំពើហិង្សា

នៅតំបន់ទីក្រុង ស្ត្រីទាំងអស់បាននិយាយថាការស្វែងរកជំនួយពីអាជ្ញាធរប្រភេទណាក៏ដោយដូចជានគរបាលជាដើម គឺមានការពិបាកណាស់សំរាប់ពួកគាត់ដោយសារតែមូលហេតុមួយចំនួន។ ជាដំបូងបង្អស់ ដោយសារតែពួកគាត់ជាសកម្មជនដីធ្លី អាជ្ញាធរចាត់ទុកពួកគាត់ថាជាអ្នកបង្កបញ្ហា ហើយដូច្នេះអាជ្ញាធរមិនទំនងជាធ្វើអ្វីមួយដើម្បីជួយពួកគាត់នោះទេ។ សកម្មជនទាំងឡាយដែលមានកេរ្តិ៍ឈ្មោះល្បី បាននិយាយថាពួកគាត់ភ័យខ្លាចថាប្រសិនបើអាជ្ញាធរបានដឹងអំពីអំពើហិង្សាក្នុងគ្រួសាររបស់ពួកគាត់ អាជ្ញាធរនឹងមិនត្រឹមតែមិនព្រមជួយពួកគាត់ទេ ប៉ុន្តែពួកគេអាចនឹងប្រើព័ត៌មាននេះដើម្បីបង្ខូចកត្តិយសរបស់ពួកគាត់ទៀតផង។ ស្ត្រីម្នាក់ក្នុងចំណោមនោះបាននិយាយថានគរបាលមូលដ្ឋានរបស់គាត់ជាញឹកញាប់តែងតែតាមដានគាត់ និងត្រួតពិនិត្យរាល់អ្វីៗ



នគរបាល រារាំងការដើរក្បួនរបស់សកម្មជនស្ត្រី ក្នុងទិវាសិទ្ធិនារីអន្តរជាតិ ក្នុងរាជធានីភ្នំពេញ កាលពីខែមីនា ឆ្នាំ២០១៤

## ករណីសិក្សា

ស្វាមី និងក្រុមគ្រួសាររបស់ខ្ញុំមិនចូលចិត្តយុទ្ធនាការរបស់ខ្ញុំទេ។ ពួកគេព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំនៅពេលខ្ញុំចេញទៅ ហើយពួកគេក៏ព្រួយបារម្ភអំពីកង្វះប្រាក់ចំណូលព្រោះពេលខ្ញុំចេញទៅធ្វើយុទ្ធនាការ ខ្ញុំមិនអាចរកប្រាក់បានទេ។

ស្វាមីរបស់ខ្ញុំមិនចង់ឲ្យខ្ញុំទៅទេ។ គាត់អនុញ្ញាតឲ្យខ្ញុំទៅតែម្តងប៉ុណ្ណោះក្នុងដប់លើក ប៉ុន្តែខ្ញុំមិនគោរពតាមគាត់ទេហើយនៅតែចេញទៅ។ នៅពេលខ្ញុំត្រឡប់មកវិញ តែងតែមានការទាស់ទែងគ្នា ជាពិសេស បន្ទាប់ពីយើងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ ប៉ុន្តែខ្ញុំអាណិតសហគមន៍ ដូចនេះ ខ្ញុំក៏បន្តធ្វើយុទ្ធនាការ។ ស្វាមីរបស់ខ្ញុំ ឲ្យខ្ញុំជ្រើសរើសរវាងក្រុមគ្រួសាររបស់ខ្ញុំ និងសហគមន៍។ បន្ទាប់ពីមានជម្លោះ ក៏បានធ្វើឲ្យយើងចែកផ្លូវគ្នា ហើយនៅខែតុលាឆ្នាំមុន យើងក៏លែងលះគ្នា។

បញ្ហាជាច្រើនតែងតែកើតឡើងនៅឆ្នាំមុន នៅពេលខ្ញុំចំណាយពេលច្រើន លើយុទ្ធនាការ ហើយខ្ញុំធ្លាប់មិនចូលផ្ទះរហូតដល់ម៉ោង ៩ ឬ ១០ យប់ ហើយស្វាមីរបស់ខ្ញុំគិតថាខ្ញុំបានធ្វើអ្វីខុស ហើយមានការសង្ស័យយ៉ាងខ្លាំង។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំគ្រាន់តែទៅធ្វើការងារជាមួយស្ត្រី និងព្រះសង្ឃ ប៉ុន្តែគាត់មិនជឿខ្ញុំទេ។ គាត់និយាយថា ខ្ញុំស្រលាញ់ដីសហគមន៍ច្រើនជាងគ្រួសារ។ គាត់ខឹងយ៉ាងខ្លាំងនៅពេលខ្ញុំត្រូវបានគេបាញ់ទឹកដាក់ ហើយរលូតកូន។ គាត់ខឹងរហូតដល់ប្រើប្រាស់អំពើហិង្សាលើខ្ញុំ។ គាត់ មិនអាចទទួលយកបានតទៅទៀតទេ។ ពីមុន គាត់មិនដែលប្រើប្រាស់អំពើហិង្សាលើខ្ញុំទេ គ្រាន់តែស្តីបន្ទោសប៉ុណ្ណោះ។

ខ្ញុំមិនបានទទួលជំនួយខាងក្រៅទេ ព្រោះខ្ញុំគិតថាវាជាកំហុសរបស់ខ្ញុំ ដែលខ្ញុំមិនអាចផ្តល់ដល់ក្រុមគ្រួសារ។ ខ្ញុំមានអារម្មណ៍ខុសឆ្គង ដែលមិនបានផ្តល់ដល់កូនរបស់ខ្ញុំ។ សហគមន៍បានជួយ និងយកខ្ញុំទៅមន្ទីរពេទ្យ នៅពេលខ្ញុំរងរបួសពេលមានអំពើហិង្សា។ ពួកគេជួយខ្ញុំម្តងនៅពេល ខ្ញុំបានព្យាយាមលោតពីលើស្ពាន។ ពួកគេបញ្ឈប់ខ្ញុំ។

បញ្ហាទាំងអស់ជះឥទ្ធិពលដល់កូនរបស់ខ្ញុំយ៉ាងច្រើន។ ពួកគេធំល្មមនឹងយល់អ្វីដែលកំពុងកើតឡើងនៅក្នុងគ្រួសារ។ ពួកគេព្រួយបារម្ភអំពីសុខភាព និងអំពីសុវត្ថិភាពរបស់ខ្ញុំ នៅពេលខ្ញុំចេញទៅធ្វើ

ដែលគាត់ធ្វើ ដូច្នេះគាត់គ្មានជំនឿថាអ្នកទាំងនោះនឹងជួយគាត់នោះទេ។ស្ត្រីម្នាក់ទៀតដែលធ្លាប់ឆ្លងកាត់បទពិសោធន៍អំពើហិង្សាឃោរឃៅនៅក្នុងគ្រួសារ បាននិយាយថាគាត់នៅទីបំផុតបានទៅសុំជំនួយពីនគរបាល ប៉ុន្តែពួកគេបានប្រាប់គាត់ថាវាជារឿងរ៉ាវក្នុងគ្រួសារ ហើយអ្នកទាំងនោះមិនបានធ្វើសកម្មភាពអ្វីទាល់តែសោះដើម្បីជួយគាត់។ ក្នុងចំណោមស្ត្រីដទៃទៀត ដែលចូលរួមបទសម្ភាសន៍ គ្មានស្ត្រីណាម្នាក់បានទៅរកអាជ្ញាធរដើម្បីសុំជំនួយនោះទេ។ ក្នុងចំណោមនោះ ស្ត្រី ២នាក់ ដែលទទួលរងអំពើហិង្សា បានឈានទៅដល់ការព្រមព្រៀងក្រៅផ្លូវការមួយជាមួយនឹងស្វាមីពួកគាត់ គឺការផ្តាច់ទំនាក់ទំនងគ្នា ការចែករំលែកទ្រព្យសម្បត្តិ និងសិទ្ធិធ្វើជាអាណាព្យាបាលរបស់កូន។ អ្នកទាំងពីរបានទៅរកអង្គការមិនមែនរដ្ឋាភិបាលដើម្បីសុំប្រឹក្សាផ្លូវច្បាប់អំពីសិទ្ធិរបស់ពួកគាត់ក្នុងការលែងលះ។

សំរាប់អ្នកដែលរស់នៅសហគមន៍ជនបទ កង្វល់ដូចគ្នាអំពីការទាក់ទងអាជ្ញាធរក៏មានដែរ ប៉ុន្តែស្ត្រីដែលត្រូវបានសម្ភាសន៍ ក៏បាននិយាយអំពីឧបសគ្គមួយចំនួនបន្ថែមទៀតសំរាប់គាត់ក្នុងការស្វែងរកជំនួយ។ ជាទូទៅនគរបាលតែងតែនៅឆ្ងាយពីភូមិ ដែលស្ត្រីរស់នៅ ហើយស្ត្រីមិនមានប្រាក់ដើម្បីធ្វើដំណើរទៅជួបនគរបាល ជាងនេះទៅទៀត គឺប្រាក់ដើម្បីស្វែងរកបណ្តឹងតាមផ្លូវច្បាប់មួយចំពោះស្វាមីរបស់អ្នកទាំងនោះ។ វាក៏ពិបាកសំរាប់ពួកគាត់ផងដែរ ក្នុងការចាក់ចេញពីស្វាមីរបស់គាត់ ដោយសារតែមូលហេតុជាក់ស្តែង ដូចជាពួកគាត់មានប្រាក់តិចតួច និងជាធម្មតាមានកូនច្រើននាក់ដែលគាត់ត្រូវមើលថៃ ហើយគាត់គ្មានកន្លែងណាដើម្បីទៅនោះទេ។ ពួកគាត់ក៏ជួបប្រទះនិងសំពាធសង្គមដ៏ខ្លាំងមួយផងដែរក្នុងការបន្តអាពាហ៍ពិពាហ៍។ឧទាហរណ៍ស្ត្រីជាច្រើននាក់ដែលចូលរួមបទសម្ភាសន៍ បានសុំអោយមេភូមិរបស់ពួកគាត់ជួយដោះស្រាយអំពើហិង្សារបស់ស្វាមីពួកគាត់។ ជាទូទៅ មេភូមិៗតែងតែនិយាយថាអំពើហិង្សានេះគឺជាបញ្ហាក្នុងគ្រួសារ ហើយពួកគេនឹងមិនធ្វើអន្តរាគមន៍ ឬក៏បែរជានិយាយថាការលែងលះគឺជារឿងអាក្រក់ ហើយស្ត្រីគួរតែត្រលប់ទៅផ្ទះវិញនៅពេលដែលស្វាមីពួកគាត់ស្ងប់ចិត្ត។ ប៉ុន្តែនៅពេលមេភូមិជួយអន្តរាគមន៍វិញ គឺវាតែងតែធ្វើឡើងដើម្បីនាំអោយស្វាមី និងភរិយាស្រុះស្រួលគ្នាវិញ។ ចំពោះករណីខ្លះ អន្តរាគមន៍នេះ គឺរួមមានការចុះហត្ថលេខារបស់ស្វាមី លើការព្រមព្រៀងថាគាត់នឹងមិនប្រើអំពើហិង្សានៅពេលអនាគត។ ដូច្នេះនៅជនបទ ស្ត្រីទាំងអស់ដែលរងទុក្ខដោយអំពើហិង្សាមានអារម្មណ៍ថាពួកគាត់គ្មានជម្រើសណាក្រៅពីនៅជាមួយស្វាមីពួកគាត់ ទោះបីជាស្ត្រីជាច្រើននាក់ក្នុងចំណោមនោះបានទទួលស្គាល់ថា ស្វាមីគាត់មិនត្រឹមតែប្រើអំពើហិង្សាលើគាត់នោះទេ ប៉ុន្តែក៏ប្រើអំពើហិង្សាលើកូនពួកគាត់ផងដែរ។ នេះហាក់បីដូចជាមានភាពអត់ធ្មត់ចំពោះអំពើហិង្សា និងការទទួលយកថាអំពើហិង្សា គឺគ្រាន់តែជាផ្នែកមួយនៃអាពាហ៍ពិពាហ៍។

## ករណីសិក្សា (ត)

យុទ្ធនាការ ដូចនេះពួកគេស្អប់សហគមន៍។ វាក៏មានឥទ្ធិពលដល់ការសិក្សារបស់ពួកគេផងដែរ។ពួកគេមិនទៅរៀនទៀងទាត់ទេ ដូចនេះខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនបានបំពេញកាតព្វកិច្ចរបស់ខ្ញុំជាម្តាយ ក៏ព្រោះតែបញ្ហានេះ។ ខ្ញុំពិបាកចិត្តព្រោះដោយធ្វើយុទ្ធនាការ ខ្ញុំនឹងទទួលបានវត្ថុមួយ តែខ្ញុំនឹងបាត់បង់វត្ថុមួយផ្សេងទៀត។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរធ្វើឲ្យបានល្អជាងនេះ សម្រាប់ក្រុមគ្រួសាររបស់ខ្ញុំ។ ជាមួយយុទ្ធនាការ យើងនៅមិនទាន់សម្រេចគោលដៅរបស់យើង ពេញលេញនៅឡើយ។ ប៉ុន្តែខ្ញុំបានដើរបានជាងពាក់កណ្តាលផ្លូវហើយ ខ្ញុំមិនអាចត្រឡប់ក្រោយទេ។

សកម្មជនដីធ្លីនៅទីក្រុង



ស្ត្រីចូលរួមក្នុងការតវ៉ាឲ្យមានការដោះលែងសកម្មជនកម្មករទាំង២៣នាក់ ក្នុងរាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៤

## ករណីសិក្សា៖ សកម្មជនដីធ្លីនៅជនបទ

ជម្លោះបានចាប់ផ្តើមនៅឆ្នាំ២០០២ ប៉ុន្តែខ្ញុំមិនចាំថាពេលណាខ្ញុំចាប់ផ្តើមធ្វើយុទ្ធនាការនោះទេ។ ជាលទ្ធផលនៃយុទ្ធនាការ យើងទទួលបានដីធ្លីរបស់យើងត្រលប់មកវិញ តែមិនទាំងអស់ទេ។ ខ្ញុំបានចូលរួមក្នុងយុទ្ធនាការ ជាច្រើនដង។ យើងបានព្យាយាមយ៉ាងខ្លាំង ដើម្បីទទួលបានដីត្រឡប់មកវិញ។ យើងបានទៅជាច្រើនកន្លែង ដូចជាខេត្តសៀមរាប និងរាជធានីភ្នំ ពេ ញ យើងក៏បានសម្រាកនៅមុខតុលាការទៀតផង។ មានតែខ្ញុំទេ ដែ ល បានចូលរួមក្នុងយុទ្ធនាការ ហើយស្វាមីរបស់ខ្ញុំនៅផ្ទះជាមួយកូនៗ។

ដំបូង គាត់គាំទ្រខ្ញុំ ប៉ុន្តែជាច្រើនដងក្រោយៗមក ដោយមិនមានលទ្ធផល ហើយជាច្រើនយប់ ច្រើនថ្ងៃ ឆ្ងាយពីផ្ទះ គាត់អស់សង្ឃឹម ហើយឥឡូវគាត់មិនចង់ឲ្យខ្ញុំទៅទៀតទេ។ មានភាពតានតឹងជាច្រើននៅក្នុងគ្រួសារ។ បញ្ហាចំបងគឺ ស្ថានភាពសេដ្ឋកិច្ចក្នុងគ្រួសារ ព្រោះខ្ញុំទៅធ្វើយុទ្ធនាការ ដូចនេះ យើងមិនមានចំណូលទេ។

គាត់ចាប់ផ្តើមប្រើហិង្សាមកលើខ្ញុំ បន្ទាប់ពីមានជម្លោះដីធ្លីបានចាប់ផ្តើម។ គាត់នឹងខឹង បន្ទាប់ពីខ្ញុំត្រឡប់មកផ្ទះពីការធ្វើយុទ្ធនាការ ហើយយើងបានឈ្លោះគ្នា ហើយបន្ទាប់មកគាត់បានប្រើហិង្សាលើខ្ញុំ។ ឥឡូវ អំពើហិង្សាបានថមថយបន្តិច ព្រោះចាប់តាំងពីយើងទទួលបានដីពាក់កណ្តាលត្រលប់មកវិញ ខ្ញុំទៅធ្វើយុទ្ធនាការតិចជាងមុន ហើយឥឡូវខ្ញុំអាចធ្វើការបានច្រើន ដែលធ្វើឲ្យយើងមិនសូវឈ្លោះគ្នាច្រើនទៀតទេ។ ប៉ុន្តែពេលខ្លះ គាត់ស្រវឹង ហើយលើកឡើងនូវបញ្ហាចាស់ៗ បន្ទាប់មកគាត់ខឹង ហើយក៏ប្រើហិង្សាម្តងទៀត។ ជាធម្មតាខ្ញុំរត់ចេញ ដើម្បីជៀសពីការវាយដំ។ខ្ញុំស្នាក់នៅផ្ទះបងប្អូន ឬផ្ទះអ្នកជិតខាង។ គាត់មិនដេញតាមខ្ញុំទេ។ ពេលខ្លះមិត្តភក្តិផ្តល់យោបល់ដល់គាត់ឲ្យឈប់ប្រើអំពើហិង្សា ហើយគាត់ហាក់ដូចជាស្តាប់ ប៉ុន្តែនៅពេលគាត់ស្រវឹង គាត់ភ្លេចអស់។

កូនបានរត់ចេញពីផ្ទះនៅពេលគាត់ខឹង ហើយគាត់ចាប់ផ្តើមជេរកូនទាំងនោះ។

លើកដំបូង នៅពេលហិង្សាបានកើតឡើង ខ្ញុំបានរាយការណ៍ទៅមេភូមិជាអ្នកដែលមកនិយាយជាមួយគាត់ ប៉ុន្តែក្រោយមកទៀតខ្ញុំមិនបានទៅរំខានទៀតទេ។ ខ្ញុំបានព្យាយាមរត់ចេញពីគាត់ ហើយអត់ធ្មត់ជាមួយគាត់។ ប្រសិនបើហិង្សាកើតឡើងទៀត ហើយធ្ងន់ធ្ងរ ខ្ញុំនឹងស្វែងរកការជួយពីអង្គការមិនមែនរដ្ឋាភិបាល ដែលអាចផ្តល់យោបល់ដល់គាត់ ឬអប់រំឲ្យគាត់ឈប់ប្រើអំពើហិង្សា។

> "ខ្ញុំមិនដែលប្តឹង នគរបាល អាជ្ញាធរ ក្នុងតំបន់ ឬអង្គការមិនមែនរដ្ឋាភិបាលឲ្យជួយខ្ញុំទេ ដោយជាទូទៅ គឺពឹងតែអ្នកជិតខាង។ ខ្ញុំបានរាយការណ៍វាទៅមេភូមិ។ គាត់បាន និយាយថា នេះជារឿងក្នុងគ្រួសារ ដូចនេះ គាត់មិនជ្រៀតជ្រែកនោះទេ។"
>
> សកម្មជនដីធ្លីនៅជនបទ

ដោយសារការធ្វើយុទ្ធនាការ ខ្ញុំមានភាពក្លាហានឥឡូវនេះ។ សហគមន៍ស្ថិតក្រោមការគាបសង្កត់រយៈពេលយូរ ដូចនេះយើងត្រូវជំនះ ហើយខ្ញុំមិនខ្លាចទៀតទេនៅពេលខ្ញុំជំនះជាមួយអ្នកដទៃទៀត។ ខ្ញុំដឹងថាខ្ញុំមានសិទ្ធិស្មើគ្នា ដូចនេះខ្ញុំមិនគួរទទួលរងទុក្ខនោះទេ។ ហើយជាមួយស្វាមីរបស់ខ្ញុំ ខ្ញុំមិនខ្លាចគាត់ដូចមុននោះទេ។ នៅពេលគាត់ខឹង ពេលខ្លះខ្ញុំតបតទៅគាត់ ព្រោះប្រសិនបើខ្ញុំស្ងាត់កាន់តែខ្លាំង គាត់កាន់តែគាបសង្កត់លើខ្ញុំ ដូច្នេះ ពេលខ្លះខ្ញុំនិយាយ។ ឥឡូវនេះខ្ញុំមិនសូវខ្លាចគាត់ទេ ប៉ុន្តែមិនមែនមិនខ្លាចទាំងស្រុងនោះទេ។




សកម្មជនជាស្ត្រី ចូលរួមទាមទារឲ្យមានការដោះលែងសកម្មជនដីធ្លីដែលកំពុងជាប់ឃុំ អ្នកស្រី យ៉ោម បុប្ផា ក្នុងរាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៤

# សេចក្តីសន្និដ្ឋាន

ការសិក្សានេះ ព្យាយាមដើម្បីស្វែងរកទំនាក់ទំនងរវាងជម្លោះដីធ្លី និងជាពិសេសភាពសកម្មនិយមរបស់ស្ត្រីដែលពាក់ព័ន្ធក្នុងជម្លោះទាំងនោះ ហើយនិងអំពើហិង្សាក្នុងគ្រួសារ និងការបែកបាក់គ្រួសារ។ បទសម្ភាសន៍ទាំងនេះបានបង្ហាញអោយឃើញថាវិវាទដីធ្លីមានផលប៉ះពាល់ធំទូលាយទៅលើស្ត្រីសកម្មជន ទាំងផ្នែកហិរញ្ញវត្ថុ សតិអារម្មណ៍ និងគ្រួសារ ហើយចំពោះករណីភាគច្រើន ផលប៉ះពាល់ទាំងនោះបានផ្លាស់ប្តូរជីវិតរបស់ស្ត្រីទាំងនោះយ៉ាងជ្រាលជ្រៅ និងមិនអាចត្រលប់ទៅភាពដើមបានឡើយ។

ចរិតលក្ខណៈនៃការសិក្សានេះ មានន័យថាយើងមិនអាចធ្វើការសរុបពីលទ្ធផល ដែលបានរកឃើញទៅលើស្ត្រីសកម្មជនដីធ្លីទាំងអស់នោះទេ ប៉ុន្តែវាគួរអោយភ្ញាក់ផ្អើលដែល ៥នាក់ក្នុងចំណោមស្ត្រី ២៤នាក់ដែលត្រូវបានសម្ភាសន៍ បានទទួលរងអំពើហិង្សាក្នុងគ្រួសារ បន្ទាប់ពីពួកគាត់ក្លាយជាអ្នកធ្វើយុទ្ធនាការ ដែលគាត់មិនធ្លាប់មានបទពិសោធន៍នេះពីមុនទាល់តែសោះ។ ហើយស្ត្រី ៦នាក់ ផ្សេងទៀតដែលធ្លាប់មានបទពិសោធន៍អំពើហិង្សាក្នុងគ្រួសារ មុនពេលជម្លោះដីធ្លីរបស់ពួកគាត់ចាប់ផ្តើម បាននិយាយថាអំពើហិង្សានេះបានកាន់តែអាក្រក់ឡើងចាប់តាំងពីពេលជម្លោះដីធ្លីចាប់ផ្តើម។

សំរាប់ស្ត្រីដែលត្រូវបានសម្ភាសន៍ ទំនាក់ទំនងរវាងជម្លោះដីធ្លី និងបទពិសោធន៍នៃអំពើហិង្សាក្នុងគ្រួសារ ហាក់បីដូចជាកើតចេញឡើងពីភាពសកម្មនិយមរបស់ពួកគាត់។ ហើយភាពសកម្មនិយមនេះ បាននាំគាត់អោយចេញពីប្រពៃណីដែលភរិយាត្រូវនៅផ្ទះ ដែលជាតួនាទីមួយដែលរង្វង់មហាជនរំពឹងថាស្ត្រីនឹងគោរពតាម។ ស្ត្រី ២ ឬ ៣នាក់ បានបញ្ចេញយោបល់អំពីបញ្ហានេះដោយខ្លួនគាត់ផ្ទាល់ ដោយនិយាយថា ដរាបណាពួកគាត់ធ្វើអ្វីៗទាំងអស់ដែលស្វាមីគាត់ចង់បានដោយមិនប្រកែក នោះទំនាក់ទំនងរបស់ពួកគាត់គឺល្អ។ នៅពេលដែលពួកគាត់មិនបានធ្វើបែបនេះ ហើយបែរជាធ្វើអ្វីដែលស្វាមីគាត់ឃើញថាជាការជ្រើសរើសសហគមន៍ជាជាងគ្រួសារ និងការទទួលយកតួនាទីជាសកម្មជនសហគមន៍ នោះស្វាមីគាត់នឹងមិនអាចទទួលយកតួនាទីថ្មីរបស់គាត់បានទេ ហើយប្តីគាត់បានប្រើអំពើហិង្សាចំពោះគាត់។

វាគួរអោយបារម្ភណ៍ដែលស្ត្រី ៧នាក់ ក្នុងចំនោមស្ត្រីដែលមានបទពិសោធន៍អំពើហិង្សាក្នុងគ្រួសារ មិនបានធ្វើសកម្មភាពអ្វីឡើយ ដើម្បីដកខ្លួនពួកគាត់អោយចេញពីស្វាមីដ៏ឃោរឃៅរបស់អ្នកទាំងនោះ តែមានការលើកលែងចំពោះម្នាក់ដែលចាកចេញពីស្វាមី គឺគាត់មិនស្វែងរកជំនួយពីនគរបាលនោះទេ។ ទោះជាយ៉ាងណាក៏ដោយ មានភាពដូចគ្នាទៅនឹងចំនួនភាគច្រើននៃជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ នៅក្នុងប្រទេសកម្ពុជា។ ស្ត្រីនៅក្នុងការសិក្សានេះបានដឹងថាការទៅរកនគរបាល មិនទំនងជាអាចជួយអោយស្ថានភាពកាន់តែប្រសើរឡើងនោះទេ ហើយគាត់ថែមទាំងត្រូវចំណាយប្រាក់ដែលគាត់គ្មាន ឬ មិនមានលទ្ធភាពអាចចំណាយបាន។ ទាំងនេះត្រូវបានផ្សំឡើងដោយការពិត ដែលថាស្ត្រីតិចតួចណាស់ដែលមានជម្រើសផ្សេងៗចំពោះកន្លែងស្នាក់នៅ ហើយការធ្វើជាអាណាព្យាបាលតែម្នាក់ឯង អាចនឹងផ្តល់ការលំបាកណាស់ដល់ពួកគាត់ក្នុងការចិញ្ចឹមជីវិត។ ដោយសារតែមុខងាររបស់អ្នកទាំងនោះជាសកម្មជនដីធ្លី ការភ័យខ្លាចរបស់ស្ត្រីដែលថានគរបាលអាចនឹងមិនជួយគាត់ និងអាចប្រើប្រាស់ព័ត៌មាននេះដើម្បីធ្វើបាបគាត់ បានចែកករណីទាំងអស់នេះ ដាច់ចេញពីករណីអំពើហិង្សាក្នុងគ្រួសារផ្សេងៗទៀត ហើយការភ័យខ្លាចនេះ គឺជាមូលហេតុដ៏ធ្ងន់ធ្ងរដែលគួរអោយព្រួយបារម្ភ។

អំពើហិង្សាលើស្ត្រី និងការរំលោភយកដីធ្លី គឺជាការបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុត និងមានទ្រង់ទ្រាយធំបំផុតនៅក្នុងប្រទេសកម្ពុជា។ សំរាប់ស្ត្រីជាច្រើននាក់នៅក្នុងការសិក្សានេះ បញ្ហាទាំងពីរនេះជាប់ទាក់ទងគ្នា ហើយជីវិតរបស់គាត់ត្រូវបានញាំញីដោយសារតែជម្លោះទាំងនៅសារធរណៈ និងនៅក្នុងទីលំនៅដ្ឋាន។ រឿងរ៉ាវរបស់ស្ត្រីទាំងនេះបានបង្ហាញអោយឃើញពីសេចក្តីក្លាហាន និងភាពអត់ធ្មត់ដ៏អស្ចារ្យរបស់ពួកគាត់ ហើយវាបានធ្វើការលាតត្រដាងនូវតម្រូវការនៃការផ្លាស់ប្តូរដ៏ពិតប្រាកដមួយទៅលើឆន្ទៈ និងគោលនយោបាយដែលបញ្ហាទាំងពីរនេះគួរតែត្រូវធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។

[៣] Katherine Brickell, Baureaksmey Prak & Bunnak Poch ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ គម្លាតរវាតច្បាប់ និងការអនុវត្តន៍នៅក្នុងប្រទេសកម្ពុជា និងអ្វីដែលអាចធ្វើបាន, របាយការណ៍ស្រាវជ្រាវបឋម ឆ្នាំ២០១៤ ទំព័រ៣៦ http://www.katherinebrickell.com/katherinebrickell/wp-content/uploads/2014/01/DV-Law-Prelim-Report-2014.pdf.

[៤] ជិត ៣៣% នៃបុរសខ្មែរដែលត្រូវបានស្ទង់មតិ ត្រូវបានរាយការណ៍ថាពួកគាត់បានប្រព្រឹត្តបទល្មើសអំពើហិង្សាលើរាងកាយ ឬអំពើហិង្សាផ្លូវភេទ ឬទាំងពីរ៖ Partners for Prevention, Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the UN Multi-country Study on Men and Violence in Asia and the Pacific, September 3013, http://www.partners4prevention.org/node/515

[៥] សូមមើលកំណត់សំគាល់ខាងលើ។

## អនុសាសន៍

►►► ត្រូវធានាថានគរបាលនឹងស៊ើបអង្កេតករណីអំពើហិង្សាក្នុងគ្រួសារទាំងអស់អោយបានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ ដោយមិនគិតពីអត្តសញ្ញាណរបស់ជនរងគ្រោះ ហើយត្រូវធានាថាអាជ្ញាធរមូលដ្ឋាន នគរបាល និងបុគ្គលិកតុលាការ ធ្វើការដោយឯករាជ្យ និងដោយយុត្តិធម៌ ដើម្បីការពារជនរងគ្រោះទាំងអស់ពីអំពើហិង្សាក្នុងគ្រួសារ។

►►► ត្រូវផ្តល់ថវិកាបន្ថែមទៅដល់នគរបាល និងជាពិសេសនគរបាលនៅជនបទ សំរាប់ធ្វើការស៊ើបអង្កេត និងការផ្តន្ទាទោសលើករណីអំពើហិង្សាក្នុងគ្រួសារ។

►►► ត្រូវធានាថាអាជ្ញាធរមូលដ្ឋាន នគរបាល និងបុគ្គលិកតុលាការ ដឹងថាអំពើហិង្សាក្នុងគ្រួសារមិនមែនជាបញ្ហាឯកជន ឬបទល្មើសស្រាល និងត្រូវធានាថាអ្នកទាំងនោះយល់ដឹងអំពីសារៈសំខាន់នៃការដាក់ទោសជនល្មើសនៃអំពើហិង្សាក្នុងគ្រួសារចំពោះសកម្មភាពរបស់ពួកគេ។

►►► បង្កើនចំនួននៃសេវាកម្មទីជម្រក និងសេវាកម្មសង្គម សំរាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ និងបង្កើតនូវការផ្តល់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

►►► បញ្ឈប់ការប្រើប្រាស់អំពើហិង្សា លើអ្នកធ្វើយុទ្ធនាការដីធ្លី និងអ្នកតវ៉ាដោយអហិង្សាទាំងអស់។

►►► ធ្វើការបញ្ឈប់ដ៏ពិតប្រាកដមួយ ចំពោះការបណ្តេញចេញដោយបង្ខំ និងត្រូវផ្តល់សំណងសមស្រប និងគ្រប់គ្រាន់ទៅដល់អ្នកដែលត្រូវបានផ្លាស់ប្តូរទីលំនៅដោយបង្ខំរួចទៅហើយ ឬអ្នកដែលត្រូវបានរឹបអូសយកដីធ្លីដោយខុសច្បាប់។

►►► ប្រតិបត្តិនូវការបើកចំហរជាសាធារណៈ និងមានតម្លាភាពនៃការកំណត់ព្រំដែន និងការបែងចែកដីធ្លី ឲ្យបានកាន់តែឆាប់ ហើយត្រូវធានាថាកម្មវិធីផ្តល់ប្លង់កម្មសិទ្ធិដីធ្លីនៅពេលអនាគតនឹងត្រូវធ្វើឡើងក្រោមដែនសមត្ថកិច្ចនៃស្ថាប័នរដ្ឋមួយដែលសមរម្យ។

www.licadho-cambodia.org